**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច**

ការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង

# សាកលវិទ្យាល័យ គ្រប់គ្រង និង សេដ្ឋកិច្ច
# ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ
# ឆ្នាំ ២០១០-២០១៥

## I- សេចក្តីផ្តើម

ក្នុងរយៈកាលជាង ១ ទសវត្សកន្លងមកនេះ ប្រទេសកម្ពុជា មានការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យនានាគួរឲ្យកត់សម្គាល់យ៉ាងខ្លាំងទាំងផ្នែករដ្ឋ និងឯកជន ដោយអនុវត្តន៍តាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណនេយ្យភាព និង អភិបាលកិច្ចល្អជាស្នូលក្នុងកសាងមាតុភូមិអង្គរដ៏បវររុងរឿងឲ្យមានការលូតលាស់រីកចម្រើនដូចជាប្រទេសផ្សេងៗនៅលើពិភពលោកក្នុងបរិបទសាកលលោកភាវូបនីយកម្មនិងសេដ្ឋកិច្ចទីផ្សារសេរី ។ ដោយក្នុងនោះដែរ វិស័យអប់រំនៅកម្ពុជា បានដើរតួយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយចីរភាពនិងជាសសៃឈាមសេដ្ឋកិច្ចរបស់សង្គមជាតិមួយពុំអាចខ្វះបាន។ ការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់កម្រិតឧត្តមសិក្សា ជាបុព្វហេតុដ៏ចម្បងជាងគេ ឆ្ពោះទៅរកប្រភពចលករការងារនិងភាពជាអ្នកដឹកនាំប្រកបដោយភាពវាងវៃ ក្លាហាន និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដឹកនាំនាវាកម្ពុជាទៅរកសុខសន្តិភាព និង ការអភិវឌ្ឍបន្ថែមទៀតនាពេលអនាគត ។ ដើម្បីធានាបាននូវការអប់រំមួយប្រកបដោយគុណភាព សមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងវិជ្ជាជីវៈការងាររបស់និស្សិតគ្រប់រូប ការអប់រំបណ្តុះបណ្តាលចាំបាច់ត្រូវកំណត់នូវយុទ្ធសាស្ត្រដែលមានលក្ខណៈច្បាស់លាស់មកធ្វើជាមូលដ្ឋានសម្រាប់អនុវត្តន៍ ប្រកបដោយប្រសិទ្ធភាពយូរអង្វែងដោយស្របតាមកំនើនប្រជាជន និងតម្រូវការ នៅលើទីផ្សារជាក់ស្តែង ។

កត្តាដំបូងដែលមានសារៈសំខាន់ជាងគេនៅក្នុងទិសដៅនៃការអប់រំ គឺការធានាបាននូវកម្មវិធីសិក្សាមួយមានស្តង់ដារច្បាស់លាស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិត និងសាធារណជនទូទៅក្នុងសង្គម ។ ជាក់ស្តែង សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចបានជ្រើសរើស និងកំណត់នូវកម្មវិធីសិក្សារបស់ខ្លួនស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ជាពិសេសកម្មវិធីសិក្សាត្រូវបានរៀបចំឡើងជាលក្ខណៈប្រព័ន្ធក្រេឌីត ដែលបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) ។ មិនតែ

ប៉ុណ្ណោះ ការសិក្សារបស់និស្សិតគ្រប់វិស័យទាំងអស់ទាំងកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ តម្រូវឲ្យធ្វើការសិក្សាស្រាវជ្រាវជាមូលដ្ឋាន ដើម្បីវាស់វែងនូវចំណុចខ្លាំង និងចំណុចខ្វះខាត របស់និស្សិតដែលកំពុងតែសិក្សា និងក្រោយពេលបញ្ចប់ការសិក្សារបស់ខ្លួន ។

ដើម្បីសម្រេចទិសដៅខាងលើ សាកលវិទ្យាល័យ បានយកចិត្តទុកដាក់នឹងជម្រុញឲ្យមានការអភិវឌ្ឍ និងពង្រឹងគុណភាពលើកត្តាបីជាមូលដ្ឋានគឺៈ រចនាសម្ព័ន្ធគ្រប់គ្រង ធនធានសាស្រ្តាចារ្យ និង លក្ខណៈគ្រប់គ្រាន់របស់និស្សិត ។

ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រង សាកលវិទ្យាល័យមាន ក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ សាកលវិទ្យាធិការរង នាយកសាខា ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន-អនុប្រធានដេប៉ាតឺម៉ង់ ប្រធាន-អនុប្រធានការិយាល័យ និង បុគ្គលិកតាមការិយាល័យ ដែលអនុវត្តតាមគោលការណ៍ " **ភារកិច្ច និង ការទទួលខុសត្រូវ** " ។ អមជាមួយនឹងកិច្ចការគ្រប់គ្រង សាកលវិទ្យាល័យ បានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ឆ្លើយតបទៅនឹងបរិបទសង្គមខ្មែរ និង លក្ខណៈជាស្តង់ដារអន្តរជាតិ ដោយមានចំនួនម៉ោងសិក្សាច្រើន ដែលនៅក្នុងនោះមានបញ្ចូលទាំងភាសាអង់គ្លេស សម្រាប់គ្រប់មុខជំនាញទាំងអស់ ក្នុងទិសដៅលើកកម្ពស់សមត្ថភាពនិស្សិត ក៏ដូចជាកិត្យានុភាពរបស់សាកលវិទ្យាល័យ។ ជាងនេះទៅទៀត សាកលវិទ្យាល័យ បានបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ ស្របតាមការវិវត្តន៍របស់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យាព័ត៌មាន ។

ក្រៅពីការងារពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង សាកលវិទ្យាល័យបានធ្វើការជ្រើសរើសសាស្រ្តាចារ្យ ដែលមានសមត្ថភាពខ្ពស់(កម្រិតវប្បធម៌ បទពិសោធន៍ និង និយាមគរុកោសល្យ) ជំនាញឯកទេសច្បាស់លាស់ និងប្រកាន់យកគោលការណ៍ (សច្ចធម៌ យុត្តិធម៌ មនសិការ និងគុណធម៌ )នៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។ ទន្ទឹមនឹងនេះដែរ សាកលវិទ្យាល័យក៏បាននឹងកំពុងជម្រុញលើកទឹកចិត្តឲ្យសាស្រ្តាចារ្យបង្កើននូវការស្រាវជ្រាវលើជំនាញឯកទេសរបស់ខ្លួន នឹងបោះពុម្ពជាសៀវភៅ ដើម្បីផ្តល់នូវភាពងាយស្រួល ក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត ។

ការផ្តល់នូវគុណភាពសិក្សា មិនអាចកាត់ផ្តាច់បានរវាងការគ្រប់គ្រងសាស្រ្តាចារ្យ និងនិស្សិតនោះ សាកលវិទ្យាល័យបានរៀបចំជម្រុញឲ្យនិស្សិតមានវិន័យល្អក្នុងការសិក្សា ខិតខំប្រឹងប្រែងសិក្សាជាមួយសាស្រ្តាចារ្យ ការបំពេញកិច្ចការរបស់សាស្រ្តាចារ្យ ស្វ័យសិក្សា និង ការស្រាវជ្រាវនៅតាមបណ្ណាល័យ ។

ដោយឡែកចំពោះនិស្សិតវិញ សាកលវិទ្យាល័យ បានតម្រូវឲ្យនិស្សិតទាំងអស់ គោរពតាមគោលការណ៍ និង បទបញ្ជាផ្ទៃក្នុង ដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំដំណើរជីវិតរបស់ខ្លួន ដើម្បីក្លាយជា ពលរដ្ឋល្អ របស់សង្គមជាតិ ។

## II- សារចតារបស់សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច

សាកលវិទ្យាល័យបានចាប់ផ្តើមបង្កើតតាំងពីឆ្នាំ ១៩៩៨ តាមសេចក្តីប្រកាសលេខ ៩០៨ អយក.ប្រក ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ១៩៩៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានឈ្មោះថាមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញជាន់ខ្ពស់បាត់ដំបង ក្រោយមកបានធ្វើការផ្លាស់ប្តូរទៅជា វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច តាមអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០០ ដោយរាជរដ្ឋាភិបាលកម្ពុជា និងបានប្រែក្លាយទៅជា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច តាមអនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០៦ ដោយរាជរដ្ឋាភិបាលកម្ពុជា។

## III- រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាកលវិទ្យាល័យ

ដើម្បីអោយចរន្តការងារបណ្តុះបណ្តាល និងការងារគ្រប់គ្រងសាកលវិទ្យាល័យ ប្រព្រឹត្តទៅបានល្អ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចបានកំណត់ និង បែងចែកនូវតួនាទី និង ភារកិច្ច សំរាប់ដំណើរការគ្រប់គ្រង ដោយមានភ្ជាប់ជាមួយនឹងតារាងឧបសម្ព័ន្ធស្តីពីរចនាសម្ព័ន្ធគ្រប់គ្រង សាកលវិទ្យាល័យ ទាំងមូលនៅផ្នែកខាងក្រោយ។

## IV- ទស្សនវិស័យ បេសកកម្ម គុណតម្លៃ និងគោលបំណងរបស់សាកលវិទ្យាល័យ

### ១- ទស្សនៈវិស័យ

សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច ប្តេជ្ញាបណ្តុះបណ្តាលនិស្សិតឲ្យមាន គុណភាព សមត្ថភាព និង ក្រមសីលធម៌ នៅក្នុងកំរិតជាតិ និងអន្តរជាតិ។

### ២- បេសកកម្ម

**សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ប្តេជ្ញានឹងអភិវឌ្ឍធនធានមនុស្ស ឲ្យមានជំនាញវិជ្ជាជីវៈនិង ការសិក្សាស្រាវជ្រាវ ច្បាស់លាស់ប្រកបដោយគុណភាព នឹងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរួមលើក កំពស់សេដ្ឋកិច្ចរស់នៅ និងកិត្យានុភាពប្រទេសជាតិ តាមរយៈការអប់រំ និង កិច្ចសហប្រតិបត្តិការលើឆាកជាតិ-អន្តរជាតិ ផ្អែកលើគោលការណ៍ សន្តិភាព អភិបាលកិច្ចល្អ និង អហឹង្សាធម៌ជាមូលដ្ឋាន ។**

បេសកកម្មរបស់សាកលវិទ្យាល័យ ពិតជានឹងឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ពីទស្សនៈ និងការងារគ្រប់គ្រងរបស់ថ្នាក់ដឹកនាំសាកលវិទ្យាល័យទាំងបច្ចុប្បន្នកាលក៏ដូចជាអនាគត។ បេសកកម្មជា អាទិភាព ត្រូវបានកំណត់ នឹងមានចែងដូចតទៅនេះៈ

➢អភិវឌ្ឍធនធានមនុស្ស ជាមូលដ្ឋានដ៏ចាំបាច់មួយ សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកម្ពុជា។ ធនធានមនុស្ស មានន័យថា ជាមនុស្សប្រកបដោយចំណេះដឹង បំនិន គុណធម៌ និង សីលធម៌ខ្ពស់នៅក្នុងសង្គម។ ក្នុងបរិបទទីផ្សារសេរី និងសាកលភាវូបនីយកម្ម ប្រភពធនធានបញ្ញាជាមាគ៌ាដ៏មានសក្តានុពលបំផុតក្នុងការបង្កើតភាពច្នៃប្រឌិត ការគ្រប់គ្រង នឹងអភិវឌ្ឍន៍សង្គមជាតិ

អោយមានសុខសន្តិភាព និងវឌ្ឍនភាពជាយូរអង្វែង។ ដូចនេះ សាកលវិទ្យាល័យ បានកំណត់នូវការបណ្តុះបណ្តាលធនធានមនុស្ស ជាកត្តាចម្បងក្នុងបេសកកម្មរបស់ខ្លួន ។

➢ផ្តល់នូវគុណភាពអប់រំ និង ការស្រាវជ្រាវ ជាទស្សនទានដ៏ឧត្តុង្គឧត្តម ថ្លៃថ្លាបំផុត លើវិស័យអប់រំសិក្សាធិការក្នុងសាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច ពីព្រោះការប្រើប្រាស់ ប្រភពទុនដូចជា៖ សំភារៈរូបវន្ត ដែលមានលក្ខណៈទាន់សម័យ សាស្ត្រាចារ្យប្រកបដោយទេពកោសល្យបង្រៀន និង សិល្បវិធីក្នុងការផ្ទេរចំណេះដឹងជូនដល់និស្សិតគ្រប់កំរិត និងគោលការណ៍សិក្សាផ្សេងៗ ជាបច្ច័យដែលនឹងនាំឱ្យនិស្សិតមានចំណេះដឹង និងសមត្ថភាពការងារពិតប្រាកដ។ ម្យ៉ាងវិញទៀត ការកំណត់កិច្ចការសិក្សាស្រាវជ្រាវសំរាប់និស្សិត ជាបុព្វហេតុមួយប្រកបដោយទឡ្ហីករណ៍ ក្នុងការសំរេចបាននូវទស្សនៈថ្មីៗ ដើម្បីដោះស្រាយនូវបញ្ហាសង្គម ឆ្លើយតបទៅនឹងតំរូវការរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន ។

➢លើកកំពស់សេដ្ឋកិច្ចរស់នៅរបស់និស្សិត គឺជាការរួមចំណែកដ៏ធំធេងមួយរបស់សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ក្នុងការចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយនូវភាពក្រីក្រ និង អនក្ខរភាព របស់ប្រជាជនទាំងរស់នៅក្នុងទីប្រជុំ ក៏ដូចទីជនបទដាច់ស្រយាលមួយចំនួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មនេះមានន័យថានិស្សិតដែលបានទទួលនូវចំណេះដឹង និងវិជ្ជាជីវៈគ្រប់លក្ខណៈហើយ ពួកគេអាចប្រើប្រាស់នូវចំណេះដឹងទាំងនេះ ក្នុងការអភិវឌ្ឍន៍ និងលើកកំពស់សេដ្ឋកិច្ចរស់នៅរបស់ខ្លួន ឱ្យមានជីវភាពធូរធារល្អប្រសើរឡើង ដើម្បីលុបបំបាត់នូវគម្លាតរវាងអ្នកមាន និង អ្នកក្រ ។

➢លើកកំពស់កិច្ចសហប្រតិបត្តិការផ្នែកអប់រំកំរិតជាតិ និងអន្តរជាតិ គឺជាការចងសម្ព័ន្ធភាពរវាងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ជាមួយនឹងដៃគូអប់រំផ្សេងៗទៀត ទាំងថ្នាក់ជាតិ និងអន្តរជាតិ។ កិច្ចសហប្រតិបត្តិការអប់រំ ជាត្រីវិស័យមួយក្នុងការធានាបាននូវការផ្លាស់ប្តូរបទពិសោធន៍អប់រំ និងបច្ចេកវិទ្យាថ្មីៗ សំរាប់បន្តអនុវត្តបណ្តុះបណ្តាលធនធានមនុស្ស នៅក្នុងសាកលវិទ្យាល័យ។ ជាពិសេស កិច្ចសហប្រតិបត្តិការនេះ នឹងនាំឱ្យនិស្សិតបានយល់ដឹងអំពីវប្បធម៌ សេដ្ឋកិច្ចសង្គម និងនយោបាយរបស់ប្រទេសផ្សេងទៀតជាដៃគូ ក្នុងការរក្សាបាននូវសុខសន្តិភាព និងភាតរភាពនៅពិភពលោកដែលគេចាត់ទុកថាជាជំបូល ផ្ទះសម្រាប់ជ្រកកោនតែមួយ ។

➢លើកកំពស់កិត្យានុភាពជាតិ ជាបេសកកម្មរួមដែលថ្នាក់ដឹកនាំសាស្ត្រាចារ្យ និស្សិតគ្រប់រូបទាំងអស់ ប្រាថ្នាចង់បានដើម្បីលើកស្ទួយមុខមាត់សង្គមជាតិ នៅលើឆាកអន្តរជាតិ ឱ្យទទួលស្គាល់ប្រទេសកម្ពុជាថា ជាប្រទេសមួយក្នុងចំណោមប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលសំបូរបែប ខាងផ្នែកសិល្បៈវប្បធម៌ ក៏ដូចជាសិក្សាធិការអប់រំ។ លើសពីនេះទៅទៀត ការបណ្តុះបណ្តាលនិស្សិតនៅក្នុងសាកលវិទ្យាល័យ ពិតជាឆ្លុះបញ្ចាំងអំពីគំនិតអប់រំ ឱ្យនិស្សិតយល់ដឹងពីប្រវត្តិសាស្ត្រ និងវប្បធម៌របស់ជាតិខ្លួន ដែលលូតលាស់រីកចំរើន នាសម័យអតីតកាល ដើម្បីក្រេបយកនូវចំណុចវិជ្ជមានទាំងអម្បាលមាណនោះ មកអភិវឌ្ឍន៍សង្គមជាតិខ្លួន ។

➢បណ្តុះបណ្តាលអោយនិស្សិត ក្លាយជាបញ្ញវន្តមានសមត្ថភាពគ្រប់គ្រាន់ ជាមូលដ្ឋានគ្រឹះដ៏រឹងមាំសំរាប់ការកសាងបញ្ញវន្តឲ្យមានសមត្ថភាពគ្រប់គ្រាន់នៅកម្ពុជា។ ដើម្បីអោយបេសកកម្មនេះសំរេចបានទៅតាម ទស្សនៈវិស័យរបស់ខ្លួន ការបណ្តុះបណ្តាលអោយក្លាយជាបញ្ញាវន្តវាទាមទារអោយនិស្សិតគ្រប់រូបចេះប្រើប្រាស់ចំណេះដឹងប្រកបដោយសុភវិនិច្ឆ័យ នឹង មានតម្លាភាព ។

➢ផ្តល់ពុទ្ធិដល់និស្សិតឱ្យក្លាយជាអ្នកដឹកនាំល្អ និងមានអភិបាលកិច្ចល្អ បេសកកម្មនេះជាតំរូវការដ៏ចាំបាច់បំផុតសំរាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ពីព្រោះប្រទេសកម្ពុជា ជាប្រទេសមួយមាននីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដោយអាស្រ័យលើរដ្ឋធម្មនុញ្ញ ដែលត្រូវបានគេចាត់ទុកថាជាច្បាប់កំពូល សំរាប់អនុវត្តន៍នៅទូទាំងប្រទេសលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកដឹក នាំ និងពលរដ្ឋកម្ពុជាគ្រប់រូប ដែលមានអភិបាលកិច្ចល្អនោះ នឹងនាំឲ្យប្រទេសជាតិទាំងមូល មានការគោរពច្បាប់ និងចេះប្រើប្រាស់សិទ្ធិសេរីភាពនៅក្នុងរង្វង់ច្បាប់ ជាពិសេសបេសកកម្មនេះនឹងជួយកាត់បន្ថយនូវភាពអសកម្មមួយចំនួនដែលធ្វើអោយរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។

➢បណ្តុះបណ្តាលនិស្សិតអោយចេះស្រឡាញ់បរិស្ថាន សន្តិភាព និង អហឹង្សាធម៌ បេសកកម្មនេះ ពិតជានឹងលើកកំពស់ការយល់ដឹងរបស់និស្សិតទាក់ទងទៅនឹងបរិស្ថាន សន្តិភាព និងធម៌អហឹង្សា ពីព្រោះ សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច កំពុងតែមានការព្រួយបារម្ភអំពីជម្លោះ និងការប្រែប្រួលអាកាសធាតុ ដែលកើតមានឡើងនៅលើ ពិភពលោកនាពេលបច្ចុប្បន្ន។ ម៉្យាងវិញទៀត បេសកកម្មនេះនឹងជំរុញអោយនិស្សិតទាំងអស់ ចេះប្រើប្រាស់ធនធានបរិស្ថាន ប្រកបដោយសមភាព នឹងគង់វង្សយូរអង្វែង ជាពិសេសការបណ្តុះវប្បធម៌ សន្តិភាពនៅក្នុងចិត្តគំនិតរបស់និស្សិត នឹងធ្វើឱ្យសហាគមន៍ ប្រទេសជាតិ និង ពិភពលោកទាំងមូលបញ្ចៀសបាននូវបញ្ហាទំនាស់នានានៅក្នុងសង្គម។

### ៣-គុណតម្លៃ

គុណតម្លៃរបស់សាកលវិទ្យាល័យមាន៖

➢អប់រំ និងបណ្តុះបណ្តាលប្រកបដោយគុណភាព គុណតម្លៃមួយនេះត្រូវបានមជ្ឈដ្ឋានជាច្រើនទទួលស្គាល់ និងឲ្យតម្លៃខ្ពស់ទៅលើគុណភាព និង សមត្ថភាពរបស់និស្សិតទាំងកម្រិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលបានបណ្តុះបណ្តាលដោយសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច នាពេលកន្លងមក។ ជាពិសេស និស្សិតដែលកំពុងបំរើការងារនៅក្នុងស្ថាប័នរដ្ឋ និង ឯកជនត្រូវបានអង្គភាពទាំងនោះ លើកសរសើរ និងពេញចិត្តចំពោះសមត្ថភាពរបស់ពួកគេជាខ្លាំង។ គុណតម្លៃខាងលើនេះ គឺសាកលវិទ្យាល័យបានផ្សារភ្ជាប់ជាមួយនឹងធនធានសាស្រ្តាចារ្យ កម្មវិធីសិក្សា សម្ភារបរិក្ខារ និងការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្រ្ត ។

➢បណ្តុះនិស្សិតឲ្យមានភាពក្លាហានក្នុងការបញ្ចេញមតិ ចំពោះមហាជននិងសង្គម ភាពក្លាហាន និងការបញ្ចេញមតិ ជាការស្តែងចេញពីសិទ្ធិសេរីភាពរបស់និស្សិតក្នុងការចូលរួមដោយសេរី ដល់ដំណើរការអប់រំយុវជន និង យុវជនដូចគ្នានៅតាមសហគមន៍ក៏ដូចនៅតាមទីសាធារណៈ ដោយមានកម្មវិធីជាច្រើនដូចជា៖ ការអប់រំជំងឺអេដស៍ ការអប់រំអំពីផលប៉ះពាល់នៃគ្រឿងញៀនចំពោះសង្គម ។ ភាពក្លាហាននេះ កើតចេញពីសកម្មភាពសិក្សាជាក្រុមរបស់និស្សិតនៅក្នុងថ្នាក់រៀន និងការចូលរួមមតិ ដើម្បីស្វែងរកនូវវិធីសាស្ត្រល្អៗក្នុងការដោះស្រាយបញ្ហា ។

➢បណ្តុះនិស្សិតឲ្យមានភាពស្មោះត្រង់ចំពោះខ្លួនឯង ចំពោះមហាជន និងសង្គមជាតិ ។ ភាពស្មោះត្រង់ជាតម្លៃសួលមួយ ដែលគ្រប់អង្គភាពទាំងអស់លើសាកលលោកប្រាថ្នាចង់បាន ពីព្រោះ តម្លៃមួយនេះផ្អែកលើគោលការណ៍បួនយ៉ាង ដែលសាកលវិទ្យាល័យបានធ្វើការបណ្តុះបណ្តាល និស្សិតនាពេលកន្លងមកគឺ៖ ជំរុញឲ្យនិស្សិតមានឆន្ទៈក្នុងការងារ យកចិត្តទុកដាក់លើការងារដែលខ្លួនកំពុងធ្វើ មានសេចក្តីព្យាយាមក្នុងការងារ និងត្រិះរិះប្រកបដោយសុភវិនិច្ឆ័យ និងមានតម្លាភាព។

➢ អប់រំនិស្សិតប្រកបដោយក្រមសីលធម៌ខ្ពស់ ក្រមសីលធម៌ ជាសសរស្តម្ភមួយ នៃការអប់រំសំរាប់មនុស្សជាតិទាំងអស់នៅលើសាកលលោក ពីព្រោះ ក្រមសីលធម៌អាចកំណត់ឲ្យ និស្សិត បុគ្គលិក និង សាស្ត្រាចារ្យ ទាំងអស់ចេះបែងចែកត្រូវខុស ចេះឲ្យតម្លៃលើខ្លួនឯង និងអ្នកដទៃ។

➢បណ្តុះនូវមនសិការជាតិ មនសិការជាតិ ជាតម្រូវការដ៏ចាំបាច់នៃការអប់រំនៅក្នុងសាកលវិទ្យាល័យគ្រប់ គ្រង និងសេដ្ឋកិច្ច ដែលធ្វើឲ្យនិស្សិតគ្រប់រូបចេះស្រឡាញ់ និងថែរក្សាប្រទេសជាតិ អត្តសញ្ញាណជាតិ និងវប្បធម៌ ដ៏ថ្លៃថ្លារបស់ខ្លួន ជាពិសេសនិស្សិតបានយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ និងភាពរីកចំរើនរបស់ប្រទេសជាតិ នាសម័យអតីតកាល ដើម្បីយកមកអភិវឌ្ឍសង្គមឲ្យមានភាពលូតលាស់រីកចំរើន និងភាពសំបូរសប្បាយ។

## ៤- គោលបំណង

➢បង្កើនចំណេះដឹងផ្នែកការងារគ្រប់គ្រង អភិបាលកិច្ច គណនេយ្យភាព និង តម្លាភាពលើវិស័យអប់រំថ្នាក់ឧត្តមសិក្សា

➢បង្កើនកម្មវិធីសិក្សាឲ្យស្របទៅនឹងតម្រូវការទីផ្សារជាក់ស្តែង

➢អភិវឌ្ឍបន្ថែមនូវសមត្ថភាពបុគ្គលិក និង សាស្ត្រាចារ្យ

➢បង្កើនកិច្ចការងារសិក្សាស្រាវជ្រាវលើវិស័យសេដ្ឋកិច្ច និង វិទ្យាសាស្ត្រសង្គម

➢ពង្រឹងគុណភាពសិក្សារបស់និស្សិត

➢ពង្រឹងគុណភាពអប់រំរបស់សាស្ត្រាចារ្យ

➢បង្កើននូវវប្បធម៌អនុវត្តការងារជាក្រុមប្រកបដោយប្រសិទ្ធភាព

- ផ្តល់អាហារូបករណ៍ដល់និស្សិតកម្រិតថ្នាក់បរិញ្ញាបត្រ
- បន្តលើកកំពស់គុណភាពសិក្សារបស់និស្សិត
- ផ្តល់នូវការអប់រំសិក្សាបន្ថែមលើជំនាញឯកទេសដែលចាំបាច់
- បង្កើនការអភិវឌ្ឍន៍សម្ភារៈសិក្សា និង សម្ភារៈរូបវន្តនានា
- បង្កើននូវសេវាកម្មសិក្សា
- បង្កើនចំនួននិស្សិតធ្វើការបន្ថែមលើទីផ្សារការងារ
- លើកកំពស់ការចូលរួម និង អប់រំផ្សព្វផ្សាយនៅតាមសហគមន៍
- ធានាបាននូវការគ្រប់គ្រងផែនការ និង ថវិកា ឲ្យមានប្រសិទ្ធភាពខ្ពស់
- ធានាបាននូវការវាយតម្លៃគុណភាពផ្ទៃក្នុងឲ្យមានតម្លាភាព និងមិនមានអគតិ។

## V- ការវិភាគ ឱកាស និង ការប្រឈម

### ក- ឱកាស

- ស្ថានភាពសង្គមមានស្ថេរភាពផ្នែកនយោបាយ និងសន្តិសុខ
- ស្ថានភាពសេដ្ឋកិច្ចមានការកើនឡើង
- កំនើនទីផ្សារការងារ និងការកើនឡើងនៃការវិនិយោគ
- កំនើនរបស់សិស្សានុសិស្សមានការកើនឡើង
- ឱកាសស្វែងរកការងារធ្វើមានច្រើន
- មានការទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- មានកិត្តិនាមក្នុងការបណ្តុះបណ្តាលនិស្សិតពីមជ្ឈដ្ឋានខាងក្រៅ

### ខ- ការប្រឈម

- មានគ្រឹះស្ថានឧត្តមសិក្សាច្រើនក្នុងខេត្តបាត់ដំបង
- គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនយកតម្លៃសិក្សាទាប
- ជីវភាពរស់នៅរបស់ប្រជាជនមានស្ថានភាពមិនអំណោយផលដោយសារវិបត្តិសេដ្ឋកិច្ច
- តម្រូវការនៅលើទីផ្សារការងារនាពេលបច្ចុប្បន្នមិនទាន់ឆ្លើយតបទៅនឹងកម្រិតនៃការបណ្តុះបណ្តាល

## បរិយាយនូវគោលដៅ

១.ពង្រឹងលើការងារគ្រប់គ្រង អភិបាលកិច្ច គណនេយ្យភាព និងតម្លាភាពលើវិស័យអប់រំថ្នាក់ឧត្តមសិក្សា៖ ការងារគ្រប់គ្រង អភិបាលកិច្ច និងគណនេយ្យភាព គឺជាកាតព្វកិច្ចស្នូលក្នុងដំណើរការគ្រប់គ្រងអង្គភាព ឬស្ថាប័នមួយឲ្យមានប្រសិទ្ធភាព និង សម្រេចបាននូវជោគជ័យស្របតាមគម្រោងផែនការសកម្មភាព ដែលបានគ្រោងទុក។ ម៉្យាងវិញទៀត សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច បានកំណត់នូវគោលបំណងនេះឡើងដើម្បីឆ្លើយតបទៅនឹងការងារបណ្តុះបណ្តាលកម្រិតថ្នាក់ឧត្តមសិក្សានៅកម្ពុជា ម្ល៉ោះហើយ ការបង្កើននូវចំណេះដឹង និង ចំណេះធ្វើដល់បុគ្គលិកស្តីការអនុវត្តនូវគោលការណ៍ និងបទបញ្ញត្តិនានា ជាពិសេស ការទទួលខុសត្រូវទៅតាមតួនាទីនិងភារកិច្ចរបស់បុគ្គលិកជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបង្កើត នូវរប្បធមិគ្រប់គ្រងការងាររួមមួយ មានលក្ខណៈច្បាស់លាស់ត្រឹមត្រូវ នឹងមានប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានចែងថា គណនេយ្យភាព និង អភិបាលកិច្ច ជាផ្នែកមួយ ដែលមិនអាចខ្វះបាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន ។ សាកលវិទ្យាល័យរំពឹងទុកថាគោលបំណងនេះ នឹងចែករំលែកនូវពុទ្ធិដល់បុគ្គលិកសាស្ត្រាចារ្យ និងនិស្សិត ឲ្យកាន់តែយល់ច្បាស់ថែមទៀតលើការងារគ្រប់គ្រង និងអភិបាលកិច្ចដើម្បីចូលរួមលើកកំពស់វិជ្ជាជីវៈការងាររបស់ខ្លួន និង អភិវឌ្ឍសង្គមជាតិ ។

១.១ បង្កើតលក្ខន្តិកៈទូទៅស្តីពីការគ្រប់គ្រងសាកលវិទ្យាល័យ ជាបទដ្ឋានការងារមួយដ៏សំខាន់ក្នុងការអនុវត្តនូវគោលការណ៍ និងបទបញ្ជាផ្សេងៗ ដែលតាក់តែង និងរៀបចំឡើងដោយក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។ ម៉្យាងវិញទៀត គោលការណ៍ និងបទបញ្ញត្តិនានាដែលបានចែងសម្រាប់ប្រតិបត្តិ សុទ្ធតែស្របទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗទៀត ដែលជាបទដ្ឋានគតិយុត្តិ ក្នុងធានាបាននូវការអនុវត្តច្បាប់ក្នុងប្រទេសមួយ ដែលមានអធិបតេយ្យភាព និងជានីតិរដ្ឋ ។ ដើម្បីឲ្យយុទ្ធសាស្ត្រក្នុងការបង្កើតនូវលក្ខន្តិកៈទូទៅមួយនេះ សម្រេចបានតាមទស្សនវិស័យ និងបេសកកម្ម លើការងារបណ្តុះបណ្តាលរបស់ខ្លួនសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច បានកំណត់នូវសកម្មភាពជាច្រើនសម្រាប់អនុវត្តន៍ដូចខាងក្រោមនេះ៖

- ១.១.១ បង្កើតសមាសភាពចងក្រង និងព្រាងលក្ខន្តិកៈទូទៅ
- ១.១.២ ចងក្រងពង្រាងលក្ខន្តិកៈទូទៅ
- ១.១.៣ ប្រជុំពិនិត្យ និងកែសម្រួល
- ១.១.៤ ប្រជុំអនុម័តលើលក្ខន្តិកៈទូទៅ
- ១.១.៥ ផ្សព្វផ្សាយលក្ខន្តិកៈទូទៅដល់អ្នកដែលពាក់ព័ន្ធ

១.២ ការបែងចែកតួនាទីភារកិច្ចនិងការទទួលខុសត្រូវនៅតាមផ្នែកនីមួយៗ ជានីតិវិធីមួយងាយស្រួលក្នុងកំឡុងពេលអនុវត្តនូវកិច្ចការទាំងឡាយ ឲ្យមានលក្ខណៈជាប្រព័ន្ធរដ្ឋបាល និងមានប្រសិទ្ធភាពខ្ពស់។ពីព្រោះយុទ្ធសាស្ត្រនេះ បង្ហាញកាន់តែច្បាស់អំពីការអនុវត្តនូវការងាររបស់

បុគ្គលិកនីមួយៗ ដែលកំពុងតែបម្រើការងារក្នុង បរិវេណសាកលវិទ្យាល័យ ពិតជានឹងយល់ច្បាស់អំពីកាតព្វកិច្ច ករណីកិច្ច និងតួនាទីរបស់ខ្លួន។ ម៉្យាងវិញទៀត ទិសដៅមួយនេះ ក៏នឹងអាចកំណត់បានផងដែរ អំពីចំណុចខ្លាំង និងចំណុចខ្វះខាតរបស់បុគ្គលិកម្នាក់ៗនៅពេលដែលប្រតិបត្តិការងារ។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបាន សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ចត្រូវកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១.២.១ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងតាមផ្នែកនីមួយៗ

១.២.២ កំណត់តួនាទី និងភារកិច្ចតាមផ្នែកនីមួយៗ

១.២.៣ ការិយាល័យសាមីត្រូវដាក់សំណើជូនសាកលវិទ្យាធិការស្តីពីការតែងតាំងតួនាទី និងភារកិច្ចរបស់បុគ្គលិក

១.២.៤ ជម្រុញបុគ្គលិកធ្វើរបាយការណ៍ប្រចាំខែជូនគណៈ គ្រប់គ្រង

១.២.៥ តាមដាន ពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារ របស់បុគ្គលិក

១.៣ ប្រជុំផ្សព្វផ្សាយស្តីពីការបរិយាយការងារ និងការគ្រប់គ្រងបុគ្គលិក ជាយុទ្ធសាស្ត្រមួយ បង្ហាញពីទំនាក់ទំនងការងារល្អរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ និងបុគ្គលិកថ្នាក់ក្រោម ស្តីពីការងារគ្រប់គ្រង។ ការប្រជុំផ្សព្វផ្សាយនេះ ដើម្បីឲ្យបុគ្គលិកទាំងអស់បានយល់ច្បាស់អំពីតួនាទី និងភារកិច្ចរបស់ខ្លួន។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រមួយនេះ សាកលវិទ្យាល័យ បានកំណត់ និងរៀបចំនូវសកម្មភាពជាច្រើនដូចខាងក្រោមនេះ ៖

១.៣.១ ជូនដំណឹងស្តីពីការបរិយាយការងារជាលាយលក្ខណ៍អក្សរដល់បុគ្គលិក

១.៣.២ ប្រជុំណែនាំ និងចែកចាយបរិយាយការងារ

១.៤ វាយតម្លៃទៅលើការអនុវត្តការងាររបស់បុគ្គលិក ជាយុទ្ធសាស្ត្រមួយ ដែលឆ្លុះបញ្ចាំង ឲ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្វះខាតលើការប្រតិបត្តិការងាររបស់បុគ្គលិកម្នាក់។ ការវាយតម្លៃនេះ នឹងកំណត់បានច្បាស់ពីតម្រូវការមួយចំនួនដូចជា៖ ការរៀបចំ ការអនុវត្ត និង ការពិនិត្យវាយតម្លៃផែនការបុគ្គលិកសម្រាប់ពេលបន្ទាប់ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

១.៤.១ បង្កើតគណៈកម្មការវាយតម្លៃបុគ្គលិក

១.៤.២ រៀបចំទម្រង់បែបបទនៃការវាយតម្លៃ

១.៤.៣ កំណត់កាលវិភាគ និងចុះវាយតម្លៃ

១.៤.៤ បូកសរុបលទ្ធផល និងធ្វើរបាយការណ៍វាយតម្លៃ

១.៤.៥ ផ្តល់អនុសាសន៍ដើម្បីកែលម្អនូវចំណុចខ្វះខាត

១.៥ បើកវគ្គបណ្តុះបណ្តាលស្តីពីការងារគ្រប់គ្រង ជាយុទ្ធសាស្រ្តស្នូល ដើម្បីបណ្តុះបណ្តាលបុគ្គលិកទាំងអស់ឲ្យយល់ដឹងកាន់តែច្បាស់អំពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំល្អ។ ការរៀបចំវគ្គបណ្តុះបណ្តាលបុគ្គលិកស្តីពីការគ្រប់គ្រង ជាទិសដៅមួយដ៏សំខាន់ក្នុងការពង្រឹង សមត្ថភាព និងវិជ្ជាជីវៈការងាររបស់បុគ្គលិកម្នាក់ៗ។ ម្យ៉ាងទៀតវិញសោត ការបណ្តុះបណ្តាល ស្តីការងារគ្រប់គ្រងនិងគណនេយ្យភាពនេះ នឹងញ៉ាំងឲ្យបុគ្គលិកចេះប្រើប្រាស់នូវចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន ។ ដើម្បីឲ្យយុទ្ធសាស្រ្តនេះសម្រេចបាន សាកលវិទ្យាល័យបានកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

១.៥.១ ជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាលការងារគ្រប់គ្រង ដល់បុគ្គលិក

១.៥.២ រៀបចំកម្មវិធីបណ្តុះបណ្តាល

១.៥.៣ អញ្ជើញវាគ្មិនមានបទពិសោធន៍លើការងារដឹកនាំ និងគ្រប់គ្រងដើម្បីធ្វើបទបង្ហាញ

១.៥.៤ វាយតម្លៃលើលទ្ធផលនៃវគ្គបណ្តុះបណ្តាល

១.៥.៥ ចងក្រងឯកសារនៃវគ្គបណ្តុះបណ្តាល

១.៦លើកទិសដៅចម្បងលើការងារគ្រប់គ្រងនាឆ្នាំសិក្សាបន្ទាប់ ជាយុទ្ធសាស្រ្តអាទិភាពមួយផងដែរក្នុងការងារ គ្រប់គ្រងសាកលវិទ្យាល័យនាពេលបច្ចុប្បន្នក៏ដូចជាអនាគត ។ ទិសដៅជាចម្បងដែលសាកលវិទ្យាល័យ កំពុងតែយកចិត្តទុកដាក់សម្រាប់អនុវត្តន៍នោះរួមមាន៖ ធនធានសាស្រ្តាចារ្យ ធនធានសម្ភារៈ និងកម្មសិក្សាដែលបានទទួលស្គាល់ដោយក្រសួងអប់រំ និង គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ACC។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

១.៦.១ ប្រជុំបុគ្គលិក ដើម្បីកំណត់ផែនការជាអាទិភាព សម្រាប់ឆ្នាំថ្មី

១.៦.២ បែងចែកការទទួលខុសត្រូវចំពោះការងារជាអាទិភាពនីមួយៗ

១.៦.៣ អនុវត្តផែនការឆ្នាំថ្មី

១.៦.៤ វាយតម្លៃផែនការ

១.៦.៥ បូកសរុបលទ្ធផល និងផ្តល់អនុសាសន៍សម្រាប់ឆ្នាំ បន្ទាប់

២- អភិវឌ្ឍកម្មវិធីសិក្សាឲ្យស្របទៅនឹងតម្រូវការទីផ្សារការងារ កម្មវិធីសិក្សា ជាគោលបំណងមួយយ៉ាងសំខាន់ សម្រាប់ធ្វើការបណ្តុះបណ្តាលបញ្ញាស្មារតីរបស់និស្សិតឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់មូលដ្ឋាននៃមូលធនបញ្ញារបស់ខ្លួន ស្របតាមបរិបទសេដ្ឋកិច្ចទីផ្សារ និងតម្រូវការជាក់ស្តែងរបស់សង្គម ។ កម្មវិធីសិក្សានៅតាម ភូមិស្ថានសិក្សានីមួយៗ ត្រូវផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែងទៅលើវិស័យជាអាទិភាពមានដូចជា៖ សេដ្ឋកិច្ច វិទ្យាសាស្រ្ត សង្គម និងភាសាបរទេស ។ ដើម្បីធ្វើឲ្យកម្មវិធីសិក្សាមានលក្ខណៈទាន់សម័យ និង សម្បូរបែប គឺតម្រូវឲ្យ

សាស្ត្រាចារ្យបង្ហាញ និងពន្យល់នូវខ្លឹមសារមេរៀន និងអត្ថប្រយោជន៍នៃមេរៀនឲ្យបានច្បាស់លាស់ ដើម្បីបន្ស៊ីចំណេះដឹងរបស់និស្សិតទៅនឹងតម្រូវការទីផ្សារការងារជាក់ស្តែង។ ដូចនេះ កម្មវិធីសិក្សាទាំងកម្រិត បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវផ្អែកលើការសិក្សាស្រាវជ្រាវជាមូលដ្ឋាន និងការអនុវត្តកម្មសិក្សាតាមប្រព័ន្ធក្រេឌីតដែលក្រសួងអប់រំ យុវជន និងកីឡានិង គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាបានណែនាំ ។

២.១ បង្កើតបេសកកម្ម និងវត្ថុបំណងឱ្យមានសង្គតិភាពទៅតាមមហាវិទ្យាល័យនីមួយៗ ជាយុទ្ធសាស្ត្រមួយ ដែលនឹងនាំឲ្យសាកលវិទ្យាល័យកំណត់បានច្បាស់អំពីបេសកកម្ម និងវត្ថុបំណងនៃមហាវិទ្យាល័យនីមួយៗ ក្នុងទិសដៅសម្រាប់ផ្តល់ការអប់រំទាំងនាពេលបច្ចុប្បន្ន ក៏ដូចជាអនាគត។ ម្យ៉ាងទៀត ការកំណត់បែបនេះ នឹងជួយឲ្យនិស្សិតទាំងអស់បានយល់ច្បាស់អំពីជំនាញឯកទេសដែលខ្លួនជ្រើសរើសសម្រាប់អាជីពនាពេលអនាគត។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

២.១.១ ប្រជុំពិភាក្សាដើម្បីបង្កើតបេសកកម្ម និងវត្ថុបំណង សម្រាប់មហាវិទ្យាល័យនីមួយៗ

២.១.២ ប្រជុំសម្រេចលើការបង្កើតបេសកកម្ម និងវត្ថុបំណង

២.១.៣ ផ្សព្វផ្សាយពីបេសកកម្ម និងវត្ថុបំណងដល់ភាគីពាក់ព័ន្ធ

២.២បង្កើតគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា ជាយុទ្ធសាស្ត្រមួយដែលឆ្លើយតបទៅនឹងបេសកកម្មដែលបានចែងថា៖ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ត្រូវពឹងផ្អែកលើកត្តាកម្មវិធីសិក្សាជាមូលដ្ឋាន។ ដើម្បីឲ្យកម្មវិធីសិក្សាទាំងអស់មានសុពលភាព និងសមស្របទៅនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន កម្មវិធីសិក្សាត្រូវបានរៀបចំពិនិត្យ និងវាយតម្លៃឲ្យបានត្រឹមត្រូវដោយគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាកលវិទ្យាល័យ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

២.២.១ បង្កើតគោលការណ៍ និងនីតិវិធីនៃការជ្រើសរើស គណៈកម្មការ

២.២.២ ជ្រើសរើស និងតែងតាំងសមាសភាពគណៈកម្មការ

២.២.៣ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ

២.៣ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងទៅតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់នីមួយៗ

២.៣.១ ជ្រើសរើស និងតែងតាំងបុគ្គលិកគ្រប់គ្រង ទៅតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់

២.៣.២ កំណត់តួនាទី និងភារកិច្ចបុគ្គលិក

២.៣.៣ ប្រជុំផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ច

២.៤ សិក្សាស្រាវជ្រាវពីតម្រូវការលើកម្មវិធីសិក្សារបស់មជ្ឈដ្ឋានខាងក្រៅ ជាយុទ្ធសាស្ត្រមួយដែលសាកលវិទ្យាល័យ អាចនឹងរកឃើញពីតម្រូវការទីផ្សារការងារ ដើម្បីធ្វើការប្រៀបធៀបកម្មវិធីសិក្សាដែលកំពុងតែបណ្តុះបណ្តាលនិស្សិត នាពេលបច្ចុប្បន្ន ។ ការបង្កើតកម្រងសំណួរ ជាប្រភពព័ត៌មាន

មួយដ៏ចាំបាច់ ដែលស្តែងចេញ ពីការចូលរួមរបស់សាធារណជនទូទៅដែលជាម្ចាស់សហគ្រាស ក្រុមហ៊ុន និងស្ថាប័ននានាក្នុងការចូលរួមអភិវឌ្ឍន៍កម្មវិធីសិក្សាឲ្យកាន់តែមាន ប្រសិទ្ធភាពខ្ពស់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ។ ដើម្បីឲ្យយុទ្ធសាស្រ្ត សម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

២.៤.១ រៀបចំចងក្រងកម្រងសំណួរ

២.៤.២ ចែកជូន និងប្រមូលកម្រងសំណួរដល់មជ្ឈដ្ឋាន ខាងក្រៅ

២.៤.៣ ធ្វើការវិភាគ និងវាយតម្លៃលើទិន្នន័យដែល ទទួលបាន

២.៤.៤ ប្រជុំជ្រើសរើសយកនូវតម្រូវការជាអាទិភាព

២.៤.៥ ធ្វើរបាយការណ៍លទ្ធផលសរុបជូនគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា

២.៥ សិក្សាស្រាវជ្រាវពីតម្រូវការរបស់និស្សិតគ្រប់មហាវិទ្យាល័យលើកម្មវិធីសិក្សា និងមុខវិជ្ជានីមួយៗ ជាយុទ្ធសាស្រ្តដែលស្វែងរកនូវព័ត៌មានពិតដែលទទួលបានពីនិស្សិតតាមរយៈសម្រង់មតិ។ យុទ្ធសាស្រ្តនេះ អាចនឹងវាស់វែងនូវចំណេះដឹងដែលនិស្សិតទទួលបាន ជាពិសេសអាចនឹងរកឃើញនូវចំណុចខ្វះខាតដើម្បីធ្វើការកែលំអកម្មវិធីសិក្សាជាបន្តទៀត ។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាង ក្រោមនេះ ៖

២.៥.១ បង្កើតកម្រងសំណួរ

២.៥.២ ចែកជូន និងប្រមូលកម្រងសំណួរដល់និស្សិត

២.៥.៣ ធ្វើការវិភាគ និងវាយតម្លៃលើទិន្នន័យដែល ទទួលបាន

២.៥.៤ ប្រជុំជ្រើសរើសយកនូវតម្រូវការជាអាទិភាព

២.៥.៥ ធ្វើរបាយការណ៍លទ្ធផលសរុបជូនគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា

២.៦ ជម្រុញឲ្យមានការចូលរួមចងក្រង និងអភិវឌ្ឍកម្មវិធីសិក្សាពីបុគ្គលិកសិក្សា និស្សិត និងមជ្ឈដ្ឋានខាងក្រៅ ជាយុទ្ធសាស្រ្តមួយដ៏សំខាន់ក្នុងការលើកទឹកចិត្តចំពោះបុគ្គលិកសិក្សា និស្សិត និងមជ្ឈដ្ឋានខាងក្រៅ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការចូលរួមស្រាវជ្រាវនិងចងក្រងកម្មវិធីសិក្សា ពីព្រោះកម្មវិធី សិក្សាជាកិច្ចការស្នូលដើម្បីធ្វើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សឲ្យមានគុណភាពដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

២.៦.១ ធ្វើលិខិតអញ្ជើញជាផ្លូវការ

២.៦.១ ផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការអភិវឌ្ឍន៍កម្មវិធីសិក្សាដល់ភាគីពាក់ព័ន្ធ

២.៦.១ លើកទឹកចិត្តដល់អ្នកចូលរួម

២.៧ រៀបចំការបណ្តុះបណ្តាលការអភិវឌ្ឍន៍កម្មវិធី សិក្សាដល់ បុគ្គលិកសិក្សា យុទ្ធសាស្រ្តនេះគឺសំដៅដល់ការបង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាដល់បុគ្គលិកសិក្សា និងសាស្ត្រាចារ្យដើម្បីឲ្យពួកគាត់មានចំណេះដឹងបន្ថែម ក្នុងការរៀបចំចងក្រងឯកសារបង្រៀនឲ្យស្រប

តាមនិយាមគរុកោសល្យ និងលក្ខណៈវិទ្យាសាស្ត្រ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

២.៧.១ ជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាលការអភិវឌ្ឍន៍កម្មវិធីសិក្សាដល់បុគ្គលិកសិក្សា

២.៧.២ រៀបចំកម្មវិធីបណ្តុះបណ្តាល

២.៧.៣ អញ្ជើញវាគ្មិនមានបទពិសោធន៍លើការងារអភិវឌ្ឍ កម្មវិធីសិក្សាដើម្បីធ្វើបទបង្ហាញ

២.៧.៤ វាយតម្លៃលើលទ្ធផលនៃការបណ្តុះបណ្តាល

២.៧.៥ ចងក្រងឯកសារនៃការបណ្តុះបណ្តាល

២.៨ អភិវឌ្ឍសម្ភារៈឧបទ្ទេសសិក្សាឱ្យមានលក្ខណៈទាន់សម័យ ជាយុទ្ធសាស្ត្រមួយផងដែរ ក្នុងការសម្រេចបាននូវគោលបំណងរបស់សាកលវិទ្យាល័យក្នុងការផ្ទេរចំណេះដឹង ជូនដល់និស្សិត ខណៈពេលដែលបច្ចេកវិទ្យា កំពុងតែមានការអភិវឌ្ឍន៍និងភាពរីកចម្រើន។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

២.៨.១ រៀបចំគម្រោងថវិកាវិនិយោគ

២.៨.១ បំពាក់សម្ភារៈឧបទ្ទេសសិក្សាទំនើបៗ

២.៨.១ គ្រប់គ្រងថែរក្សា និងជួសជុលសម្ភារៈសិក្សា

២.៩ បង្កើតក្លឹបសិក្សាភាសាអង់គ្លេស យុទ្ធសាស្ត្រនេះ បង្ហាញឲ្យឃើញកាន់តែច្បាស់ក្នុង ការបណ្តុះបណ្តាល និស្សិតខិតខំប្រឹងប្រែងរៀនសូត្រភាសាអង់គ្លេស ពីព្រោះភាសានេះ អាចនឹងនាំ ឲ្យនិស្សិតចេះស្រាវជ្រាវ និងស្វែងរកនូវព័ត៌មានពីឯកសារផ្សេងៗ ទៀត ដែលបានសរសេរជាភាសាអង់គ្លេស។ ជាពិសេស ការសិក្សាភាសាអង់គ្លេស ក៏មានសារៈសំខាន់ផងណាស់ដែរចំពោះ ទីផ្សារការងារនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

២.៩.១ រៀបចំគោលការណ៍ក្លឹបសិក្សាភាសាអង់គ្លេស

២.៩.២ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងក្លឹបសិក្សាភាសាអង់គ្លេស

២.៩.៣ ផ្សព្វផ្សាយ និងពន្យល់ពីអត្ថប្រយោជន៍របស់ក្លឹប

២.៩.៤ ជ្រើសរើសសមាជិកក្លឹបតាមរយៈការប្រឡងចូល

២.៩.៥ បូកសរុបលទ្ធផល និងវាយតម្លៃលើការសិក្សា

២.៩.៦ ធ្វើរបាយការណ៍ និងចងក្រងទុកជាឯកសារ

៣- អភិវឌ្ឍសមត្ថភាពបន្ថែមដល់បុគ្គលិក និងបុគ្គលិកសិក្សា ការអភិវឌ្ឍបន្ថែមនូវសមត្ថភាពរបស់បុគ្គលិក និង សាស្ត្រាចារ្យ ជាគោលដៅមួយដែលពុំអាចខ្វះបាន ក្នុងការកសាង និង ពង្រីកនូវចំណេះដឹងសំរាប់សាកលវិទ្យាល័យ និង សង្គមជាតិ ។ ការអភិវឌ្ឍសមត្ថភាពរបស់សាស្ត្រាចារ្យមានន័យថាជួយពង្រឹងនិង ពង្រីកចំណេះដឹងរបស់ពួកគាត់ ឲ្យកាន់តែមានគុណភាព ក្នុងការផ្ទេរ

ចំណេះដឹងជូនដល់និស្សិតដែលជាទំពាំងស្នងឫស្សី ជាពិសេស ការអភិវឌ្ឍខ្លួន ជាប្រចាំ គឺជាអ្នកចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា។ ដោយឡែកក្នុងនោះដែរការអភិវឌ្ឍសមត្ថភាពបុគ្គលិកជាយន្តការដ៏ចាំបាច់ សម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈការងារឲ្យមានដំណើរការ ប្រព្រឹត្តទៅបានល្អលើវិស័យអប់រំថ្នាក់ឧត្តមសិក្សា ។

### ក. បុគ្គលិក

៣.១ ពង្រឹងសមត្ថភាពការងារបុគ្គលិក ជាយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីឲ្យបុគ្គលិកទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើកិច្ចការងារផ្សេងៗ លើវិស័យអប់រំថ្នាក់ឧត្តមសិក្សា ជាពិសេសយុទ្ធសាស្ត្រនេះគឺសាកលវិទ្យាល័យ នឹងទទួលបាននូវបុគ្គលិកមានសមត្ថភាពពេញលេញសម្រាប់ធ្វើការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

៣.១.១ ប្រជុំណែនាំការងារប្រតិបត្តិប្រចាំខែ

៣.១.២ តាមដានលើការងារប្រចាំថ្ងៃ

៣.២ លើកទឹកចិត្តលើគុណវុឌ្ឍិ និងស្នាដៃការងារល្អដល់បុគ្គលិក ជាយុទ្ធសាស្ត្រមួយដែលនឹងធ្វើឲ្យបុគ្គលិកមានភាពស្និទ្ធស្នាលជាមួយនឹងអ្នកគ្រប់គ្រង និងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការងាររបស់ខ្លួនដែលកំពុងតែប្រតិបត្តិ។ ម្យ៉ាងវិញទៀតយុទ្ធសាស្ត្រនេះនឹងនាំឲ្យសាកលវិទ្យាល័យ ជ្រើសរើសបាននូវបុគ្គលិកដែលមានចំណេះដឹង បទពិសោធន៍ និង មនសិការ វិជ្ជាជីវៈខ្ពស់ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

៣.២.១ ផ្តល់ប័ណ្ណសរសើរ

៣.២.២ ផ្តល់ការបញ្ចុះតម្លៃលើការសិក្សាបន្ត

៣.២.៣ តម្លើងឋានៈ និងប្រាក់បៀវត្ស

៣.៣ បណ្តុះបណ្តាលចំណេះដឹងបន្ថែមដល់បុគ្គលិក ជាយុទ្ធសាស្ត្រ មួយដែលនឹងនាំឲ្យបុគ្គលិកទាំងអស់ទទួលបាននូវចំណេះដឹងបន្ថែមលើកិច្ចការ របស់ខ្លួននាពេលបច្ចុប្បន្ន ពីព្រោះ មានតែការពង្រីកបន្ថែមនូវចំណេះដឹងនេះទេ ដែលនឹងអាចប្រែក្លាយស្ថានភាពរស់នៅនិងការងារអប់រំឲ្យស្របទៅនឹងកាលទេសៈ ប្រកួតប្រជែងនៃយុគសម័យសាកលភាវូបនីយកម្មនិងសេដ្ឋកិច្ចទីផ្សារសេរី។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

៣.៣.១ បើកវគ្គខ្លី សិក្ខាសាលា ចំណេះដឹងទូទៅ

៣.៣.១ បំប៉នលើជំនាញឯកទេស (ផ្លូវការ និងក្រៅផ្លូវការ)

៣.៣.១ បំប៉នលើភាសាអង់គ្លេស កុំព្យូទ័រ និងការប្រើប្រាស់ អ៊ិនធឺណិត

៣.៤ វាយតម្លៃទៅលើសមត្ថភាពការងាររបស់បុគ្គលិក ជាយុទ្ធសាស្ត្រដែលនឹងអាចកំណត់បានពីសមត្ថភាពការងារ និងការទទួលខុសត្រូវដោយផ្ទាល់របស់និយោជិកទាំងអស់ ដែលកំពុងតែប្រតិបត្តិ ការងារនៅតាមផ្នែកនីមួយៗក្នុងបរិវេណសាកលវិទ្យាល័យទាំងមូល ហើយយុទ្ធសាស្ត្រនេះ ក៏បង្ហាញពីគុណភាពការងាររបស់បុគ្គលិកដែលសាកលវិទ្យាល័យបានប្រគល់ឲ្យ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៣.៤.១ បង្កើតគណៈកម្មការវាយតម្លៃ

៣.៤.២ បង្កើតគោលការណ៍ និងនីតិវិធីវាយតម្លៃ

៣.៤.៣ បង្កើតទម្រង់វាយតម្លៃ

៣.៤.៤ រៀបចំកាលវិភាគ និងចុះវាយតម្លៃ

៣.៤.៥ បូកសរុបលទ្ធផលវាយតម្លៃ

៣.៤.៦ ផ្តល់អនុសាសន៍

### ខ. បុគ្គលិកសិក្សា

៣.៥ ពង្រឹងសមត្ថភាពការងារដល់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលមានសក្តានុពលជាងគេបង្អស់ក្នុងវិស័យបណ្តុះបណ្តាលធនធានមនុស្ស នៅសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ពីព្រោះសមត្ថភាពរបស់សាស្ត្រាចារ្យទាមទារចាំបាច់នូវការសិក្សា ស្រាវជ្រាវ វិភាគនិង ពិសោធន៍លើខ្លឹមសារមេរៀនដែលស្របតាមបរិបទសង្គម និង សេដ្ឋកិច្ចរបស់ប្រទេសជាតិ។ ជាពិសេសសាស្ត្រាចារ្យ ត្រូវតែមាន សមត្ថភាពគ្រប់គ្រាន់ក្នុងការ ផ្ទេរចំណេះដឹង ជូនដល់និស្សិត ដែលជាសសរទ្រូងនៃសង្គមជាតិ។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ

៣.៥.១ ប្រជុំណែនាំការងារប្រតិបត្តិប្រចាំខែ

៣.៥.២ តាមដានលើការងារប្រចាំថ្ងៃ

៣.៦ លើកទឹកចិត្តក្នុងការចូលរួមដល់បុគ្គលិក លើកទឹកចិត្តលើគុណវុឌ្ឍិ និងស្នាដៃបង្រៀនល្អដល់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលនឹងធ្វើឲ្យសាស្ត្រាចារ្យមានភាពស្និទ្ធស្នាលជាមួយនឹងអ្នកគ្រប់គ្រង និងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការងារបង្រៀនរបស់ខ្លួនដែលកំពុងតែប្រតិបត្តិ។ ម៉្យាងវិញទៀត យុទ្ធសាស្ត្រនេះនឹងនាំឲ្យសាកលវិទ្យាល័យជ្រើសរើសបាននូវសាស្ត្រាចារ្យដែលមានចំណេះដឹងបទពិសោធន៍ និងមនសិការវិជ្ជាជីវៈខ្ពស់។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

៣.៦.១ ផ្តល់ប័ណ្ណសរសើរ

៣.៦.២ ផ្តល់ការបញ្ចុះតម្លៃលើការសិក្សាបន្ត

៣.៦.៣ បង្កើនចំនួនថ្នាក់បង្រៀន

៣.៦.៤ តម្លើងឋានៈ និងប្រាក់ម៉ោង

៣.៧ ប្រជុំបច្ចេកទេស ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ជាយុទ្ធសាស្ត្រមួយ ដែលនឹងនាំឲ្យសាស្ត្រាចារ្យទាំងអស់មានភាពស្និទ្ធស្នាលចំពោះគ្នាទៅវិញទៅមកដោយមិនប្រកាន់រើសអើង។ ម៉្យាងវិញទៀត យុទ្ធសាស្ត្រនេះ គឺជាការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ ៖

៣.៧.១ កំណត់កាលវិភាគប្រជុំ

៣.៧.២ ធ្វើលិខិតអញ្ជើញ

៣.៧.៣ ធ្វើការប្រជុំបច្ចេកទេស

៣.៧.៤ កំណត់ហេតុ និងរបាយការណ៍អង្គប្រជុំ

៣.៨ បណ្តុះបណ្តាលចំណេះដឹងបន្ថែមដល់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយ ដែលនឹងនាំឲ្យសាកលវិទ្យាល័យទទួលបាននូវធនធានសាស្ត្រាចារ្យដែលចំណេះដឹង និងសមត្ថភាពខ្ពស់ក្នុងការបង្រៀននិស្សិត។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រនេះ ជំរុញឲ្យសាស្ត្រាចារ្យគ្រប់រូបទាំងអស់បានអភិវឌ្ឍនូវចំណេះដឹងរបស់ខ្លួន ឲ្យស្របទៅតាមការរីកចំរើនខាងវិទ្យាសាស្ត្របច្ចេកវិទ្យា និងកាលទេសនិយម។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ ៖

៣.៨.១ បើកវគ្គខ្លី សិក្ខាសាលា ចំណេះដឹងទូទៅ

៣.៨.២ បំប៉នលើជំនាញឯកទេស (ផ្លូវការ និងក្រៅផ្លូវការ)

៣.៩ វាយតម្លៃលើសមត្ថភាពបង្រៀនរបស់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលនឹងនាំឲ្យសាកលវិទ្យាល័យកំណត់បាននូវសមត្ថភាពបង្រៀនពិតៗរបស់សាស្ត្រាចារ្យម្នាក់ៗ។ ជាពិសេសជាងនេះទៅទៀតនោះ ការវាយតម្លៃនេះ ក៏នឹងបង្ហាញផងដែរ នូវការយកចិត្តទុកដាក់បង្រៀន និងការងារអប់រំបណ្តុះបណ្តាលរបស់ពួកគាត់ម្នាក់ៗ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

៣.៩.១ បង្កើតគណៈកម្មការវាយតម្លៃ

៣.៩.២ បង្កើតគោលការណ៍ និងនីតិវិធីវាយតម្លៃ

៣.៩.៣ បង្កើតទម្រង់វាយតម្លៃ

៣.៩.៤ រៀបចំកាលវិភាគ និងចុះវាយតម្លៃ

៣.៩.៥ បូកសរុបលទ្ធផលវាយតម្លៃ

៣.៩.៦ ផ្តល់អនុសាសន៍

៤.បង្កើតឲ្យមានកិច្ចការស្រាវជ្រាវ កិច្ចការស្រាវជ្រាវ ជាគោលបំណងមួយដែលមានប្រភពជាក់លាក់ និង ប្រាកដប្រាជានិយម ពីព្រោះ ការសិក្សាជ្រាវស្រាវ ធ្វើឲ្យនិស្សិត រកឃើញនូវប្រភពបញ្ហា ការកំណត់នូវបញ្ហា និង ការដោះស្រាយនូវបញ្ហា ។ ម៉្យាងវិញទៀត ការស្រាវជ្រាវ

លើវិស័យសេដ្ឋកិច្ច និង វិទ្យាសាស្ត្រសង្គម អាចជាមាត្រដ្ឋានមួយច្បាស់លាស់ ក្នុងការវាស់វែងចំណេះដឹង និងសមត្ថភាពរបស់និស្សិតដែលកំពុងតែសិក្សានិងក្រោយពីបញ្ចប់ការសិក្សា។ ដើម្បីឲ្យគោលបំណងនេះសម្រេចបានស្របតាមទស្សនវិស័យ និងបេសកកម្មរបស់ខ្លួន ធនធានឯកសារនិងសាស្ត្រាចារ្យ ជាជំនួយមួយយ៉ាងសំខាន់ក្នុងការស្វែងរកប្រភពព័ត៌មាន និង ជាភស្តុតាងដែលបង្ហាញពីទឡ្ហីករណ៍ទាក់ទង ទៅនឹងដែនកំណត់ប្រធានបទមួយ អាចយកជាការណ៍បានសម្រាប់និស្សិតជំនាន់ក្រោយទៀត យកមកធ្វើជា លំអានសិក្សាស្រាវជ្រាវ។

៩.១ បង្កើតគណៈកម្មការសិក្សាស្រាវជ្រាវ ជាយុទ្ធសាស្ត្រមួយដ៏សំខាន់លើវិស័យបណ្តុះបណ្តាលឧត្តមសិក្សា ពីព្រោះការសិក្សាស្រាវជ្រាវទាមទារឲ្យមានគណៈកម្មការគ្រប់គ្រង និងប្រឹក្សាយោបល់ឲ្យបានត្រឹមត្រូវប្រកបដោយគុណភាពខ្ពស់។ ម៉្យាងវិញទៀត គណៈកម្មការនេះ នឹងធានាបាននូវចែកជូនទ្រឹស្តីចំណេះដឹង និងការអនុវត្តជាក់ស្តែងទាំងការអប់រំនិងបណ្តុះបណ្តាលពីរបៀបនៃការស្រាវជ្រាវ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

- ៩.១.១ បង្កើតគោលការណ៍ និងនីតិវិធីនៃការជ្រើសរើស គណៈកម្មការ
- ៩.១.២ ជ្រើសរើស និងតែងតាំងសមាសភាពគណៈកម្មការ
- ៩.១.៣ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ

៩.២ បើកវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាស្រាវជ្រាវ ជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់ ដើម្បីឲ្យអ្នកសិក្សាទាំងឡាយយល់កាន់តែច្បាស់ពីរបៀបប្រមូលព័ត៌មាន វិភាគព័ត៌មាន និង សន្និដ្ឋានលើលទ្ធផលដែលខ្លួនទទួលបានតាមរយៈការសិក្សាស្រាវជ្រាវ។ លើសពីនេះទៅទៀត និស្សិតនឹងចេះចាំពីរបៀបធ្វើការស្រាវជ្រាវបែបប្រៀបធៀបក៏ដូចជាវិភាគលើទ្រឹស្តីជាមួយ នឹងស្ថានភាពជាក់ស្តែងប្រកបដោយចំណេះដឹងនិងវិចារណញាណខ្ពស់។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

- ៩.២.១ ជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាលលើការសិក្សាស្រាវជ្រាវ
- ៩.២.២ រៀបចំកម្មវិធីបណ្តុះបណ្តាល
- ៩.២.៣ អញ្ជើញវាគ្មិនមានបទពិសោធន៍លើការងារស្រាវជ្រាវដើម្បីធ្វើបទបង្ហាញ
- ៩.២.៤ វាយតម្លៃលើលទ្ធផលនៃការបណ្តុះបណ្តាល
- ៩.២.៥ ចងក្រងឯកសារនៃការបណ្តុះបណ្តាល

៩.៣កំណត់ប្រធានការសិក្សាស្រាវជ្រាវឱ្យស្របទៅនឹងបរិបទសង្គម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាយុទ្ធសាស្ត្រមួយដែលនឹងអាចធ្វើឲ្យសាកលវិទ្យាល័យទទួលបានអ្នកសិក្សាស្រាវជ្រាវប្រកបដោយចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ ជាពិសេសយុទ្ធសាស្ត្រនេះគឺធ្វើឡើងដើម្បីវាស់វែងពីសមត្ថភាព និងកម្រិតយល់ដឹងរបស់និស្សិតគ្រប់រូបដែលចេះប្រើប្រាស់ចំណេះដឹងពិតក្នុង

កិច្ចការការស្រាវជ្រាវ។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ ៖

៤.៣.១ បង្កើតគោលការណ៍ និងនីតិវិធីស្រាវជ្រាវ

៤.៣.២ ប្រជុំកំណត់ប្រធានបទ និងវិសាលភាពស្រាវជ្រាវ

៤.៣.៣ បង្កើតក្រុមសិក្សាស្រាវជ្រាវ និងអនុវត្តការស្រាវជ្រាវ

៤.៣.៤ វាយតម្លៃលើលទ្ធផលនៃការស្រាវជ្រាវ

៤.៣.៥ ផ្សព្វផ្សាយពីលទ្ធផល និងរបកគំហើញនៃការសិក្សា ស្រាវជ្រាវ

៤.៣.៦ លើកទឹកចិត្តដល់និស្សិត បុគ្គលិក និងបុគ្គលិកសិក្សា ដែលបានធ្វើការសិក្សាស្រាវជ្រាវ

៥.ពង្រឹងគុណភាពសិក្សារបស់និស្សិត ការពង្រឹងគុណភាពសិក្សា គឺជាតម្លៃស្នូលមួយ ដែលគណៈគ្រប់គ្រងសាកលវិទ្យាល័យបន្តកំពុងតែនឹងអនុវត្ត នឹង ខិតខំប្រឹងប្រែងអនុវត្តបន្តទៀត ពីព្រោះភាពជោគជ័យដែល សាកលវិទ្យាល័យទទួលបាន នឹង ឈររឹងប៉ឹងរហូតមកដល់ពេលសព្វថ្ងៃនេះ បានក៏ព្រោះអាស្រ័យតែនឹង ការផ្តោតយកចិត្តទុកដាក់លើគុណភាពសិក្សារបស់និស្សិតជាចម្បង ។ គុណភាពសិក្សាមានន័យថា ការផ្តល់នូវ ចំណេះដឹង និងវិជ្ជាជីវៈដល់និស្សិតផ្អែកលើគោលការណ៍គ្រឹះបីយ៉ាងសំខាន់គឺ ពុទ្ធិ បំនិន និង ក្រមសីលធម៌ ។ នាពេលកន្លងមក សាកលវិទ្យាល័យបានផ្លាស់ប្តូរនូវយុទ្ធសាស្ត្ររបស់ខ្លួនខ្លះ ក្នុងការពង្រឹង គុណភាពសិក្សា របស់និស្សិតទាំងកម្រិតបរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ឲ្យរឹតតែមានគុណភាពដើម្បីសម្របសម្រួល ការសិក្សាតាមសាកលលោកភាវូបនីយកម្ម និង ចរន្តសេដ្ឋកិច្ចទីផ្សារសេរី ។

៥.១ ការជ្រើសរើសនិស្សិត យោងតាមប្រកាសលេខ ៨៥០ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីបទបញ្ជាជ្រើសរើសនិស្សិតឲ្យចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា បានបង្ហាញត្រង់ប្រការ ១ ថា៖ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវកំណត់ចំនួនជ្រើសរើសនិស្សិតឲ្យចូលរៀន ឲ្យបានសមស្រម តាមនិយាមគរុកោសល្យ។ ដូច្នេះ ការជ្រើសរើសនិស្សិតឲ្យចូលសិក្សា ជាកត្តាមួយដ៏សំខាន់ក្នុងការពង្រឹងគុណភាពរបស់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៥.១.១ បង្កើតគណៈកម្មការជ្រើសរើសនិស្សិត

៥.១.២ បង្កើតគោលការណ៍ និងនីតិវិធីជ្រើសរើសនិស្សិត

៥.១.៣ បង្កើតគោលការណ៍ និងនីតិវិធីជ្រើសរើសនិស្សិត អាហារូបករណ៍

៥.១.៤ ជ្រើសរើសនិស្សិតទៅតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា

៥.១.៥ បង្កើតគោលការណ៍ និងនីតិវិធីជ្រើសរើសនិស្សិតផ្ទេរចូល

៥.១.៦ ពិនិត្យផ្ទៀងផ្ទាត់សញ្ញាបត្រ និងឯកសារពាក់ព័ន្ធ

៥.១ ការគ្រប់គ្រងវិន័យ ជាយុទ្ធសាស្ត្រមួយដែលអាចកំណត់បានពីភារកិច្ច និងការទទួលខុសត្រូវចំពោះការគ្រប់គ្រងលើកិច្ចបង្រៀននិងសិក្សារបស់និស្សិត ដើម្បីធានានូវការសិក្សាអប់រំមួយប្រកបដោយគុណភាពនិងជួយឲ្យនិស្សិតទទួលបាននូវការអប់រំចរិយាធម៌ ក្នុងការធ្វើខ្លួនរបស់និស្សិតឲ្យក្លាយទៅជានិស្សិតល្អ កូនល្អ និងពលរដ្ឋនៅក្នុងសង្គមកម្ពុជា ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៥.១.១ បង្កើតគណៈកម្មការវិន័យ

៥.១.២ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង

៥.១.៣ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការវិន័យ

៥.១.៤ រៀបចំការប្រជុំស្តីពីបញ្ហាវិន័យ

៥.១.៥ អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៥.១.៦ បូកសរុបរបាយការណ៍លទ្ធផល

៥.២ ការពិគ្រោះយោបល់

៥.២.១ បង្កើតគណៈកម្មការពិគ្រោះយោបល់

៥.២.១ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង

៥.២.១ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ

៥.២.១ ផ្តល់ប្រឹក្សាយោបល់

៥.២.១ បូកសរុបរបាយការណ៍លទ្ធផល

៥.៣ គ្រប់គ្រងសកម្មភាពសិក្សារបស់និស្សិត ជាយុទ្ធសាស្ត្រមួយ ដែលនឹងអាចធ្វើឲ្យសាកលវិទ្យល័យ ងាយស្រួលតាមដាននូវសកម្មភាពសិក្សារបស់និស្សិតគ្រប់កម្រិតសិក្សាទាំងអស់ឲ្យរឹងរឹតកាន់តែចូលរួមយ៉ាងសកម្មនឹងខិតខំប្រឹងប្រែងសិក្សារៀនសូត្រដើម្បីអនាគតរបស់ពួកគេ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

៥.៣.១ តាមដានវត្តមានរបស់និស្សិត

៥.៣.១ សម្រង់ពិន្ទុរបស់និស្សិត

៥.៣.១ ផ្តល់ប្រឹក្សា និងបំប៉នបន្ថែមសម្រាប់និស្សិតខ្សោយ

៥.៣.១ ផ្តល់ព័ត៌មានសិក្សារបស់និស្សិតដល់អាណាព្យាបាល

៥.៤ ការរៀបចំដំណើរការប្រឡងរបស់និស្សិត ជាយុទ្ធសាស្ត្រមួយដើម្បីធ្វើឱ្យឃើញច្បាស់អំពីលទ្ធផលនៃការសិក្សារបស់និស្សិតគ្រប់មុខវិជ្ជាសិក្សាទាំងអស់ ស្របតាមកម្មវិធិសិក្សាដែលសាកលវិទ្យាល័យបានរៀបចំហើយ យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តឡើងដើម្បីធ្វើការវាស់វែងពីកំរិតយល់ដឹងរបស់និស្សិតគ្រប់មុខវិជ្ជាសិក្សានីមួយៗ ដែលបានកំណត់តាមរយៈ Course Outline។

ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៥.៤.១ បង្កើតគណៈកម្មការរៀបចំការប្រឡង

៥.៤.២ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនៃការ ប្រឡង

៥.៤.៣ ជូនដំណឹងពីការប្រឡង

៥.៤.៤ រៀបចំវិញ្ញាសារប្រឡង

៥.៤.៥ ប្រជុំណែនាំ និងបែងចែកតួនាទីភារកិច្ច

៥.៤.៦ ប្រកាសលទ្ធផលប្រឡង

៥.៤.៧ បូកសរុបរបាយការណ៍

៥.៥ ពង្រឹងកិច្ចការសិក្សាស្រាវជ្រាវរបស់និស្សិត ជាយុទ្ធសាស្ត្រមួយដែលជំរុញឲ្យ និស្សិតគ្រប់ភូមិស្ថានសិក្សាទាំងអស់ យល់កាន់តែច្បាស់ពីអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ពីព្រោះមានតែការសិក្សាស្រាវជ្រាវនេះទេ អាចនឹងជួយដល់និស្សិតខិតខំស្វែងបន្ថែមទៀតរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅសង្គម ដែលពួកគេកំពុងតែរស់នៅ ជាពិសេស និស្សិតអាចបង្កើននូវលទ្ធភាពកាន់តែខ្ពស់នៃការសិក្សា។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៥.៥.១ ជម្រុញសាស្ត្រាចារ្យដាក់កិច្ចការស្រាវជ្រាវដល់ និស្សិត

៥.៥.២ ធ្វើការណែនាំអំពីរបៀបនៃការស្រាវជ្រាវ

៥.៥.៣ និស្សិតត្រូវធ្វើបទបង្ហាញអំពីលទ្ធផលនៃការ ស្រាវជ្រាវ

៥.៥.៤ វាយតម្លៃលើលទ្ធផលស្រាវជ្រាវ

៥.៥.៥ លើកទឹកចិត្តនិស្សិតដែលទទួលបានលទ្ធផលល្អ

៥.៥.៦ រក្សាទុកស្នាដៃនៃការស្រាវជ្រាវរបស់និស្សិត

៥.៦ វង្វាយតម្លៃការសិក្សារបស់និស្សិត ជាយុទ្ធសាស្ត្រដែលអាចនឹងធានានូវការអប់រំបណ្តុះបណ្តាលដល់និស្សិតប្រកបដោយគុណភាពនិងមានសមត្ថភាពជាក់ស្តែង តាមរយៈការវាយតម្លៃទៅលើចុងបញ្ចប់នៃលទ្ធផលសិក្សា របស់និស្សិតគ្រប់មុខវិជ្ជាសិក្សានីមួយៗ ។ ម៉្យាងវិញទៀត យុទ្ធសាស្ត្រនេះត្រូវធ្វើឡើងផ្អែកលើគោលការណ៍ ៣ យ៉ាងសំខាន់ៗ គឺ៖ ការគ្រប់គ្រង ការត្រួតពិនិត្យ និងការវាយតម្លៃ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាង ក្រោមនេះ៖

៥.៦.១ ការគ្រប់គ្រងលើលទ្ធផលនៃការសិក្សា

៥.៦.២ ការពិនិត្យលទ្ធផលនៃការប្រលងជាក់ស្តែង

៥.៦.៣ ការវិភាគ និង វង្វាយតម្លៃទៅលើលទ្ធផលជារួម

៥.៦.៤ ធ្វើរបាយការណ៍សរុបជូនគណៈគ្រប់គ្រង

៥.៧ ការបណ្តុះបណ្តាលបន្ថែមសម្រាប់និស្សិតខ្សោយ ជាយុទ្ធសាស្ត្រមួយដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីធ្វើការឆ្លើយតបទៅនឹងគោលបំនងរបស់សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច ក្នុងការធានាបាននូវប្រេពលភាពនៃគុណភាពអប់រំបណ្តុះបណ្តាលនិស្សិត ប្រកបដោយលក្ខខណ្ឌស្មើៗគ្នា។ ម៉្យាងវិញទៀតយុទ្ធសាស្ត្រនេះអាចនឹងឆ្លើយតបទៅបរិបទមួយដែលកំណត់ថា អ្នកចេះច្រើនជួយបង្ហាត់បង្ហាញ អ្នកចេះតិច រីឯអ្នកចេះតិច ជួយបង្ហាត់បង្ហាញដល់ អ្នកដែលមិនចេះសោះ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៥.៧.១ ពិនិត្យលទ្ធផលប្រចាំឆមាស

៥.៧.២ រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់និស្សិតខ្សោយ

៥.៧.៣ ជូនដំណឹងអំពីកម្មវិធីបណ្តុះបណ្តាល

៥.៧.៤ បើកវគ្គបណ្តុះបណ្តាល

៥.៧.៥ វាយតម្លៃលើលទ្ធផលនៃការបណ្តុះបណ្តាល

៥.៧.៦ បូកសរុបការងារបណ្តុះបណ្តាល

៥.៨ ការបណ្តុះបណ្តាលចំណេះដឹងបន្ថែមដល់និស្សិត ជាយុទ្ធសាស្ត្រ អាចនឹងកំណត់ពីភាពជោគជ័យលើ មុខវិជ្ជាសិក្សានីមួយៗ របស់និស្សិតចាប់តាំងពីកម្រិតបរិញ្ញាបត្រ រហូតដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ពីព្រោះយុទ្ធសាស្ត្រនេះ ធ្វើឲ្យគណៈគ្រប់គ្រងផ្នែកសិក្សាធិការអប់រំ និងផ្នែកផ្សេងទៀតដែលជាប់ពាក់ព័ន្ធ អាចសន្និដ្ឋានលើភាពខ្លាំង និង ភាពខ្សោយរបស់និស្សិតដែលកំពុងតែសិក្សាគ្រប់ឯកទេសនីមួយៗ។ ម៉្យាងវិញទៀតសាកលវិទ្យាល័យ អាចកំណត់បានពីភាពពេញចិត្តរបស់និស្សិតទៅលើវិស័យសិក្សាណាមួយ ដែលមានវិសាលភាពខ្លាំងជាងគេ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៥.៨.១ បើកវគ្គបណ្តុះបណ្តាលចំណេះដឹងទូទៅ

៥.៨.២ បើកវគ្គបណ្តុះបណ្តាលក្រមសីលធម៌

៥.៨.៣ បើកវគ្គបណ្តុះបណ្តាលជំនាញឯកទេស

៥.៨.៤ សិក្ខាសាលា និងបទបង្ហាញ

៦. ពង្រឹងគុណភាពអប់រំរបស់បុគ្គលិកសិក្សា ការផ្ទេរចំណេះដឹងដល់និស្សិត ជាធនធានដ៏ចម្បងក្នុងការពង្រីកចំណេះដឹង ពីមនុស្សមួយជំនាន់ ទៅមនុស្សមួយជំនាន់ទៀតក្នុងបរិបទអប់រំ ។ ក៏ប៉ុន្តែអ្វីដែល សំខាន់ជាងគេនោះ គឺគុណភាពអប់រំ របស់សាស្ត្រាចារ្យ ក្នុងការបង្ហាត់បង្រៀននិស្សិតឲ្យឃើញច្បាស់ អំពីតម្លៃនៃការអប់រំ ដើម្បីឲ្យពួកគេទាំងអស់ គ្នាក្លាយទៅជាពលរដ្ឋល្អ អ្នកដឹកល្អសម្រាប់សហគមន៍ សង្គមជាតិ ក៏ដូចជា ពិភពលោកទាំងមូលនាពេលអនាគត ។ ការបំពេញចំណេះដឹងបន្ថែមបច្ចេកទេស នៃការបង្រៀន សកម្មភាពបង្រៀន ប្រព្រឹត្តទៅតាមនិយាម

គរុកោសល្យ នឹងផ្លាស់ប្តូរបទពិសោធន៍រវាងសាស្ត្រាចារ្យនិងសាស្ត្រាចារ្យ ជាបច្ច័យមួយយ៉ាងសំខាន់ ដើម្បីធ្វើឲ្យការបង្រៀន របស់សាស្ត្រាចារ្យមានគុណភាពល្អ ។

៦.១ បង្កើតគណៈកម្មការជ្រើសរើសបុគ្គលិកសិក្សា

៦.១.១ បង្កើតគោលការណ៍ និងនីតិវិធីនៃការជ្រើសរើស គណៈកម្មការ

៦.១.២ ជ្រើសរើស និងតែងតាំងសមាសភាពគណៈកម្មការ

៦.១.៣ កំណត់តួនាទី និងភារកិច្ចរបស់គណៈកម្មការ

៦.២ ការជ្រើសរើសបុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រដែលមួយដែលជួយឲ្យសាកលវិទ្យាល័យទទួលបាននូវសាស្ត្រាចារ្យប្រកបដោយចំណេះដឹង និង សមត្ថភាពគ្រប់គ្រាន់ក្នុងការផ្ទេរចំណេះរបស់ពួកគាត់ដល់និស្សិត។ក្រៅពីនេះដើម្បីធានាឲ្យនូវធនធានសាស្ត្រាចារ្យ សាកលវិទ្យាល័យ បានអនុវត្តនូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ៖

៦.២.១ បង្កើតគោលការណ៍ និងនីតិវិធីជ្រើសរើសបុគ្គលិកសិក្សា

៦.២.២ ជូនដំណឹងជ្រើសរើសបុគ្គលិកសិក្សា

៦.២.៣ ពិនិត្យ និងវាយតម្លៃលើឯកសារពាក់ព័ន្ធរបស់បេក្ខជន

៦.២.៤ បិទផ្សាយលទ្ធផលនៃការជ្រើសរើស និងកំណត់កាលបរិច្ឆេទសម្ភាសន៍

៦.២.៥ ប្រជុំសម្រេចធ្វើការជ្រើសរើស

៦.២.៦ ណែនាំអំពីគោលការណ៍នានារបស់សាកលវិទ្យាល័យ

៦.៣ គ្រប់គ្រង និងត្រួតពិនិត្យឯកសារបង្រៀនរបស់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយក្នុងការកំណត់ឲ្យកាន់ច្បាស់អំពីប្រភពឯកសារសម្រាប់បង្រៀននិងសិក្សាពីព្រោះមានឯកសារ គឺមានលក្ខណៈហួសសម័យក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង របត់សង្គមដែលមាន ការផ្លាស់ប្តូរជាញឹកញាប់ជាពិសេស ឯកសារមួយចំនួនត្រូវបានហាមឃាត់ដែលពាក់ព័ន្ធទៅនឹងស្ថានភាពនយោបាយ។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៦.៣.១ ប្រមូលសៀវភៅគោល ឯកសារយោង និងរក្សាទុក ឲ្យបានត្រឹមត្រូវ

៦.៣.២ ត្រួតពិនិត្យការរៀបចំប្លង់មេរៀនរបស់សាស្ត្រាចារ្យ

៦.៣.៣ ប្រមូល និងត្រួតពិនិត្យវិញ្ញាសារប្រឡងឲ្យបានមុន

៦.៣.៤ ត្រួតពិនិត្យ និងតាមដានការប្រគល់ និងទទួល វិញ្ញាសារ

៦.៣.៥ ជម្រុញសាស្ត្រចារ្យឲ្យប្រាប់ ពីប្រភពឯកសារយោង ដល់និស្សិត

៦.៤ការគ្រប់គ្រងសកម្មភាពបង្រៀនរបស់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលនឹងធានាបាននូវប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលនិស្សិតប្រកបដោយគុណភាពតម្លាភាពនិង គណនេយ្យភាពរបស់សាស្ត្រាចារ្យគ្រប់រូបក្នុងកាតព្វកិច្ចបង្រៀនរបស់ខ្លួន។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រនេះធ្វើឲ្យកាន់តែមានភាពងាយស្រួលចំពោះបុគ្គលិកសិក្សាទាំងអស់ ក្នុងការងារគ្រប់គ្រងសកម្មភាព

បង្រៀនរបស់ពួកគាត់ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៦.៤.១ កិច្ចសន្យាបង្រៀន

៦.៤.២ តាមដានសកម្មភាពបង្រៀនក្នុងថ្នាក់របស់បុគ្គលិក សិក្សា

៦.៤.៣ គ្រប់គ្រងការផ្តិតមេដៃចេញ និងចូល

៦.៤.៤ តាមដានវត្តមានរបស់បុគ្គលិកសិក្សា

៦.៤.៥ តាមដានការចុះសកម្មភាពបង្រៀនប្រចាំថ្ងៃ

៦.៤.៦ តាមដាន និងត្រួតពិនិត្យចំនួនម៉ោងបង្រៀនប្រចាំខែ

៦.៤.៧ តាមដានការគោរពបទបញ្ជាផ្ទៃក្នុង និងក្រមសីល ធម៌វិជ្ជាជីវៈរបស់បុគ្គលិកសិក្សា

៦.៥ វាយតម្លៃលើសមត្ថភាពបង្រៀនរបស់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលចូលរួមលើកកំពស់ឲ្យនិស្សិតគ្រប់រូបចេះប្រើប្រាស់នូវសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការបញ្ចេញមតិ ពីព្រោះវិធីសាស្ត្រនេះអាចនឹងឱ្យសាកលវិទ្យាល័យជ្រើសរើសបាននូវសាស្ត្រាចារ្យដែលសមត្ថភាព ចំណេះដឹង និង បទពិសោធន៍ ខណៈពេល ដែលពួកគាត់កំពុងតែបង្រៀននិស្សិត ជាពិសេស វាក៏អាចបញ្ជាក់បានផងដែរពីភាពពេញចិត្តនិងមិនពេញចិត្ត របស់និស្សិតចំពោះមុខវិជ្ជាដែលខ្លួនកំពុងតែទទួលពីលោកគ្រូនិងអ្នកគ្រូ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

ក. ការវាយតម្លៃពីនិស្សិត

៦.៥.១ រៀបចំទម្រង់វាយតម្លៃលើការបង្រៀន

៦.៥.២ ប្រមូលសម្រង់មតិវាយតម្លៃពីនិស្សិត

៦.៥.៣ ធ្វើការវិភាគទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ

៦.៥.៤ ចេញលទ្ធផលវាយតម្លៃជូនបុគ្គលិកសិក្សា និងផ្តល់ អនុសាសន៍ដើម្បីធ្វើការកែលម្អ

៦.៥.៥ ធ្វើរបាយការណ៍សរុបលើលទ្ធផលនៃការវាយតម្លៃ

៦.៥.៦ ជូនប័ណ្ណសរសើរដល់បុគ្គលិកសិក្សាដែលទទួល បានលទ្ធផលល្អ

ខ. ការវាយតម្លៃពីគណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង

៦.៥.៧ រៀបចំគោលការណ៍ និងនីតិវិធីនៃការចុះអង្កេត និងវាយតម្លៃ

៦.៥.៨ រៀបចំកាលវិភាគ ចុះអង្កេត និងវាយតម្លៃ

៦.៥.៩ ប្រមូល និងវិភាគលទ្ធផលនៃការវាយតម្លៃ

៦.៥.១០ បូកសរុបលទ្ធផលនៃការវាយតម្លៃ

៦.៥.១១ ផ្តល់អនុសាសន៍

៦.៦ បើកវគ្គបណ្តុះបបើកវគ្គបណ្តុះបណ្តាលពីបច្ចេកទេស និងវិធីសាស្ត្របង្រៀន ជាយុទ្ធសាស្ត្រមួយ ដែលនឹងជួយឲ្យសាស្ត្រាចារ្យគ្រប់រូបយល់ដឹងកាន់តែច្បាស់ពីមធ្យោបាយ នឹងគន្លឹះសំខាន់ៗ ដើម្បីធ្វើការបណ្តុះបណ្តាលអប់រំមនុស្សពេញវ័យ ពីព្រោះការអប់រំមនុស្សពេញវ័យ គឺជាការសម្របសម្រួល និង កែលំអនូវចំណុចខ្វះខាតរបស់ និស្សិត ដែលកំពុងតែជួបប្រទះ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៦.៦.១ កំណត់កម្មវិធីបណ្តុះបណ្តាល

៦.៦.២ រៀបចំវគ្គបណ្តុះបណ្តាល និងប្រជុំបច្ចេកទេស

៦.៦.៣ កំណត់កាលបរិច្ឆេទបណ្តុះបណ្តាល

៦.៦.៤ ជូនដំណឹងអំពីវគ្គបណ្តុះបណ្តាល

៦.៦.៥ អញ្ជើញបុគ្គលិកសិក្សាចូលរួម

៦.៦.៦ វាយតម្លៃលើវគ្គបណ្តុះបណ្តាល

៦.៦.៧ ធ្វើរបាយការណ៍ និងកំណត់ហេតុលើលទ្ធផល វគ្គបណ្តុះបណ្តាល

៦.៧ ក្រមសីលធម៌ វិជ្ជាជីវៈរបស់បុគ្គលិកសិក្សា ការលើកកំពស់វិជ្ជាជីវៈរបស់បុគ្គលិក្សា ជាវត្ថុបំណងមួយដ៏សំខាន់ក្នុងវិស័យអប់រំសិក្សាធិការ ពីព្រោះបុគ្គលិកសិក្សាមានតួនាទី និងភារកិច្ចជាអ្នកអប់រំ ដឹកនាំនិស្សិតឲ្យទៅជាពលរដ្ឋនៅក្នុងសង្គម។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៦.៧.១ មានតម្លាភាពលើកិច្ចការងារបង្រៀន

៦.៧.២ គោរពតួនាទី និងពេលវេលាបង្រៀន

៦.៧.៣ គោរពគោលការណ៍ បទបញ្ជាផ្ទៃក្នុង និងកិច្ចសន្យា

៦.៧.៤ សីលធម៌ក្នុងការនិយាយស្តី កាយវិការក្នុងពេល បង្រៀន

៦.៧.៥ ស្មោះត្រង់ និងយុត្តិធម៌ចំពោះនិស្សិត

៦.៨ ការអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកសិក្សា ជាយុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការបណ្តុះបណ្តាលធនធានប្រកបដោយគុណភាព ជាពិសេសយុទ្ធសាស្ត្រនេះជំរុញឲ្យសាស្ត្រាចារ្យទាំងអស់ចេះអភិវឌ្ឍន៍នូវចំណេះដឹងផ្សេងៗទៀត ឲ្យស្របទៅនឹងការរីកចំរើនខាងបច្ចេកវិទ្យា។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៦.៨.១ ផ្តល់ឱកាសឲ្យបុគ្គលិកសិក្សាចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា ក្នុងនិង

ក្រៅប្រទេស

៦.៨.២ ផ្តល់ជូនការបណ្តុះបណ្តាលអប់រំ (ផ្លូវការ និងមិនផ្លូវការ)

៦.៨.៣ ផ្តល់បុរេប្រទានដើម្បីអភិវឌ្ឍសមត្ថភាព

៦.៨.៤ ផ្តល់ជូននៅការបញ្ចុះតម្លៃចំពោះការបន្តសិក្សានៅសាកលវិទ្យាល័យ

៧.បង្កើននូវវប្បធម៌អនុវត្តន៍ការងារជាក្រុមប្រកបដោយប្រសិទ្ធភាព គោលបំណងនេះ គឺបង្ហាញឲ្យកាន់តែច្បាស់ថែមទៀតពីទិសដៅដ៏ជាក់លាក់មួយក្នុងបង្កើតវប្បធម៌អនុវត្តការងារ ជាក្រុមរបស់និស្សិតនៅសាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច លើគោលការណ៍ជួយគ្នាទៅវិញទៅមករវាងនិស្សិតនឹងសហគមន៍របស់ខ្លួនតាមរយៈកម្មវិធីអប់រំ នឹងចែករំលែកនូវធនធានដែលខ្លួនមានជួយដល់ប្រជាពលរដ្ឋកំពុងតែនឹងជួបការលំបាក ក្នុងជីវភាពរស់នៅ ជាពិសេស គោលបំណងនេះ នឹងចូលរួមដោយផ្ទាល់ជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្តារឡើងវិញនូវធនធានមនុស្សនឹងចូលរួមកាត់បន្ថយនូវភាពក្រីក្ររបស់ ប្រជាពលរដ្ឋ។

៧.១បង្កើតឲ្យមានការសិក្សាជាក្រុម ជាយុទ្ធសាស្ត្រមួយជួយឲ្យនិស្សិតទាំងអស់ ចេះធ្វើការងារជាក្រុមនឹងប្រមូលបាននូវប្រភពមតិយោបល់ សម្រាប់ការចូលរួមឆ្ពោះទៅរកប្រសិទ្ធភាពនៃការសិក្សាដែលមានលក្ខណៈសម្បូរបែប។ ការសម្រេចបាននូវយុទ្ធសាស្ត្រនេះ សាកលវិទ្យាល័យ បានកំណត់ហើយនឹង អនុវត្តនូវសកម្មភាពមួយចំនួន ដូចខាងក្រោមនេះ ៖

៧.១.១ ផ្សព្វផ្សាយកម្មវិធីសិក្សាជាក្រុម

៧.១.២ បែងចែកនិស្សិតសិក្សា

៧.១.៣ ផ្តល់ប្រធានបទសិក្សា

៧.១.៤ ឲ្យនិស្សិតធ្វើរបកគំហើញការសិក្សា

៧.១.៥ វាយតម្លៃទៅលើលទ្ធផលនៃការសិក្សា

៧.២ បង្កើតបង្កើតក្រុមនិស្សិតឆ្នើមជួយសម្របសម្រួលការសិក្សា ជាយុទ្ធសាស្ត្រមួយដែលឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ពីចក្ខុវិស័យ និងបេសកកម្មរបស់សាកលវិទ្យាល័យ ក្នុងការបណ្តុះបណ្តាលនិស្សិតឲ្យមានភាពក្លាហាន និងគុណភាពតាមរយៈការសិក្សាទ្រឹស្តីបូកផ្សំជាមួយនឹងការអនុវត្តជាក់ស្តែង នៅក្នុងសង្គម។ ដើម្បីឲ្យយុទ្ធសាស្ត្រ សម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៧.២.១ ជ្រើសរើសក្រុមនិស្សិតពូកែ

៧.២.២ រៀបចំនីតិវិធីសម្រាប់ជួយសម្របសម្រួលការសិក្សា

៧.២.៣ លើកទឹកចិត្តនិស្សិតពូកែជួយធ្វើការសម្របសម្រួល

៧.៣ បង្កើតកម្មវិធីអប់រំប្រជាពលរដ្ឋនៅក្នុងសហគមន៍ ជាយុទ្ធសាស្ត្រមួយដែលជម្រុញ និងលើកទឹកចិត្តចំពោះនិស្សិតទាំងអស់ឲ្យចេះធ្វើការងារជាមួយនឹងសហគមន៍ ដែលពួកគាត់កំពុងតែរស់នៅ ការអប់រំសហគមន៍នេះ សាកលវិទ្យាល័យបានកំណត់នូវបញ្ហាប្រឈមមួយចំនួនដែលកំពុងតែកើតមានឡើងនៅក្នុងសហគមន៍សម្រាប់ឱ្យនិស្សិតស្រាវជ្រាវ និងធ្វើការអប់រំ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេច បាន សាកលវិទ្យាល័យ បានដាក់ចេញនូវ សកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

៧.៣.១ រៀបចំគម្រោងដើម្បីចុះអប់រំប្រជាពលរដ្ឋ

៧.៣.២ ចុះទំនាក់ទំនងតាមសហគមន៍ និងអាជ្ញាធរ

៧.៣.៣ ផ្តល់អាទិភាពការងារដល់សមាគមនិស្សិតដើម្បីចុះ

៧.៣.៤ បូកសរុបរបាយការណ៍អប់រំសហគមន៍

៧.៤ វាយតម្លៃលើការងារជាក្រុមរបស់និស្សិត ជាយុទ្ធសាស្ត្រដ៏ប្រសើរមួយសម្រាប់ឲ្យ សាកលវិទ្យាល័យធ្វើសេចក្តីសន្និដ្ឋាននិងវាយតម្លៃបានទៅលើសកម្មភាពរបស់និស្សិត ដែលកំពុងតែរៀនសូត្រ និងធ្វើការងាររបៀបជាក្រុម។ លើសពីនេះទៅទៀត សាកលវិទ្យាល័យអាចនឹង កំណត់ពីភាពក្លាហាននិងសាមគ្គីភាពរវាងគ្នានិងគ្នារបស់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៧.៤.១ ចាត់តាំងសមាសភាពគណៈកម្មការវាយតម្លៃ

៧.៤.២ រៀបចំនីតិវិធីនៃការវាយតម្លៃ

៧.៤.៣ ធ្វើរបាយការណ៍លទ្ធផលការងារ

៨. ផ្តល់អាហារូបករណ៍ដល់និស្សិតកម្រិតថ្នាក់បរិញ្ញាបត្រ ការផ្តល់អាហារូបករណ៍ដល់និស្សិតជាកត្តាមួយដ៏សំខាន់ក្នុងកាត់បន្ថយនូវគម្លាតសិក្សារវាងនិស្សិតដែលមានធនធាននិង និស្សិតដែលខ្វះធនធាន និស្សិតដែលរស់នៅទីប្រជុំនិងនិស្សិតដែលរស់នៅទីជនបទ ដើម្បីឲ្យពួកគេមានឱកាសទទួល បានការអប់រំកម្រិតឧត្តមសិក្សាស្មើៗ គ្នា ក្នុងការលើកកំពស់ជីវភាពរស់នៅក្នុងគ្រួសារ នឹងអភិវឌ្ឍសង្គមជាតិរបស់ខ្លួនឲ្យមានការរីកចំរើនដូចជាអារ្យប្រទេសនានាក្នុងបរិបទតំបន់ និងសាកលលោកទាំងមូល។ ដើម្បីឲ្យការផ្តល់អាហារូបករណ៍នេះ មានដំណើរការប្រព្រឹត្តទៅបានដោយរលូននោះ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចបានកំណត់នូវគោលការណ៍ និង លក្ខខណ្ឌជ្រើសរើសនិស្សិត ដោយផ្អែកលើមូលដ្ឋាន ៣ យ៉ាង៖ ការផ្តល់ អាហារូបករណ៍តាម រយៈក្រសួងអប់រំយុវជននិងកីឡា ការផ្តល់អាហារូបករណ៍តាមរយៈមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា និងការផ្តល់អាហារូបករណ៍តាមរយៈការបើកប្រឡង អាហារូបករណ៍ជាសាធារណៈរបស់សាកលវិទ្យាល័យ គ្រប់គ្រង និង សេដ្ឋកិច្ចផ្ទាល់។

៨.១ គោលការណ៍អាហារូបករណ៍ ជាយុទ្ធសាស្ត្រមួយ ជួយឲ្យសាកលវិទ្យាល័យកំណត់ឲ្យបានកាន់តែច្បាស់ពីលក្ខខណ្ឌនិងគោលការណ៍នានា ក្នុងការធានានូវការជ្រើសរើសនិស្សិតឲ្យចូលសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ នៅតាមវិស័យដែលពួកគេចង់សិក្សានីមួយៗ

ជាពិសេសនោះ ការចុះឈ្មោះសិក្សាជានីតិវិធីមួយដ៏សំខាន់ ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញ នូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ៖

៨.១.១ គោលការណ៍អាហារូបករណ៍ត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួង អប់រំ យុវជន និងកីឡា និងសាកលវិទ្យាល័យ

៨.២ នីតិវិធីនៃការផ្តល់អាហារូបករណ៍ ជាយុទ្ធសាស្ត្រមួយដែលចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានដើម្បីឆ្ពោះទៅរកការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋតាមរយៈគោលនយោបាយអភិវឌ្ឍន៍សហវត្ស ប្រកបដោយនិរន្តរភាព ជាពិសេសការផ្តល់អាហារូបករណ៍ ដល់និស្សិតគ្រប់មជ្ឈដ្ឋានទាំងទីក្រុងក៏ដូចជាទីជនបទ បង្ហាញពីទិសស្លោកអប់រំសំរាប់យើងទាំងអស់របស់ក្រសួងអប់រំ យុវជន និង កីឡា។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួន ដូចខាងក្រោមនេះ៖

៨.២.១ ការប្រឡង

៨.២.២ ការផ្តល់តាមនិទ្ទេសប្រឡង Bac II

៨.២.៣ ការផ្តល់ឲ្យតាមអាទិភាព (នារី ក្រីក្រនិងដាច់ស្រយាល)

៨.២.៤ការផ្តល់តាមរយៈក្រសួងអប់រំ

៨.២.៥ ការផ្តល់តាមរយៈថ្នាក់ដឹកនាំ និងឥស្សរជន

៨.៣ កំណត់ប្រភេទនិងចំនួនអាហារូបករណ៍ មានទិសដៅក្នុងការកំណត់ឲ្យច្បាស់នូវប្រភេទនិងចំនួនអាហារូករណ៍ ដើម្បីចូលរួមជាមួយនឹងរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្សឆ្ពោះទៅកាន់ការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមទីក្រុង ក៏ដូចជាជនបទ។ យុទ្ធសាស្ត្រនេះ ត្រូវអនុវត្តដោយយោងទៅតាមស្ថានភាពជាក់ស្តែងរបស់សាកលវិទ្យាល័យ។

៨.៤ កម្រិតនៃអាហារូបករណ៍ (យោងតាមស្ថានភាពចំពោះមុខរបស់សាកលវិទ្យាល័យ)

៨.៣.១ អាហារូបរណ៍១០០ %

៨.៣.១ អាហារូបករណ៍៥០ %

៩-បន្តលើកកំពស់គុណភាពសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៖ គុណភាពអប់រំសម្រាប់និស្សិតថ្នាក់ក្រោយឧត្តមសិក្សាដោយផ្តោតការយកទុកសំខាន់ខ្លាំងជាងគេ គឺការសិក្សាស្រាវជ្រាវរបស់និស្សិត។ពីព្រោះ ការសិក្សាស្រាវជ្រាវរឹតតែជម្រុញឲ្យនិស្សិតទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិភាគនិង វង្វាយតម្លៃទៅ លើចំណេះដឹងរបស់ពួកគេម្នាក់ៗ ។ ទោះបីជាយ៉ាងក៏ដោយ ការគ្រប់គ្រងសកម្មភាពសិក្សាសកម្មភាពបង្រៀនកម្មវិធីសិក្សា និង សម្ភារៈសិក្សា ជាមូលដ្ឋានដ៏

ចាំបាច់មិនអាចខ្វះបានដើម្បីធានាឲ្យមានគុណភាពសិក្សារបស់និស្សិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រកបដោយ ប្រសិទ្ធភាព។

៩.១ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនិស្សិតថ្នាក់ក្រោយឧត្តមសិក្សា ជាបទដ្ឋានគតិយុត្តិមួយដ៏សំខាន់ក្នុងការគ្រប់គ្រងអវត្តមានសិក្សារបស់និស្សិត ជាពិសេសគោលការណ៍នេះ ត្រូវបានធានានូវយន្តការចូលរួមលើកកំពស់អប់រំគុណភាពសិក្សារបស់និស្សិតថ្នាក់ក្រោយឧត្តម។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះ សម្រេចបានសាកលវិទ្យាល័យកំណត់នូវសកម្មភាពដូចខាងក្រោម៖

៩.១.១ បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនិស្សិតថ្នាក់ក្រោយឧត្តមសិក្សា

៩.២ អភិវឌ្ឍកម្មវិធីសិក្សាស្របតាមបរិបទនយោបាយនិងសេដ្ឋកិច្ច ជាយុទ្ធសាស្ត្រមួយ ដែលស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចនិងនយោបាយរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន ជាពិសេសការអភិវឌ្ឍកម្មវិធីសិក្សា របស់សាកលវិទ្យាល័យត្រូវតែមានភាពចាំបាច់ណាមួយតាមតម្រូវការសង្គម និងបច្ចេកវិទ្យារីកចំរើនជាក់ស្តែង។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញ នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៩.២.១ បង្កើតបេសកកម្ម និងវត្ថុបំណងនៃមហាវិទ្យាល័យ

៩.២.២ បង្កើតសមាសភាពគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ក្រោយឧត្តមសិក្សា

៩.២.៣ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង

៩.២.៤ ផ្សព្វផ្សាយដល់អ្នកដែលពាក់ព័ន្ធ

៩.៣ ផ្តល់នូវឱកាសអប់រំគ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចសិក្សា ជាយុទ្ធសាស្ត្រមួយ ដែលនឹងត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធ្វើការសិក្សាស្រាវជ្រាវរៀនសូត្រពីព្រោះ និស្សិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គឺសាកលវិទ្យាល័យតម្រូវឲ្យនិស្សិត គ្រប់រូបធ្វើការសិក្សាស្រាវជ្រាវឲ្យបានច្រើនជាងការសិក្សា ជាមួយនឹងគ្រូបង្រៀនផ្ទាល់ ជាពិសេស ផ្អែកលើគោលការណ៍សិក្សា៤ ចំណុចសំខាន់ៗ ដូចជា៖ ការស្រាវជ្រាវ ការពិសោធន៍ ការវិភាគ និងការធ្វើសម្មតិកម្ម។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញ នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៩.៣.១ រៀបចំសិក្ខាសាលា

៩.៣.២ ចុះកម្មសិក្សា

៩.៤ ជម្រុញការសិក្សាស្រាវជ្រាវតាមប្រព័ន្ធអេឡិចត្រូនិច និង **E-library** ជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់បំផុតសម្រាប់និស្សិតគ្រប់កម្រិតសិក្សាទាំងអស់ ចេះសិក្សាស្រាវជ្រាវនឹងប្រើប្រាស់ព័ត៌មានតាមរយៈបណ្តាញអ៊ីនធឺណែត ក្នុងការប្រមូលបាននូវប្រភពសិក្សារៀនសូត្រដែលពុំចេះរីងស្ងួត។ម្យ៉ាងវិញទៀត ការធ្វើសមាហរណកម្មសិក្សាជាមួយនឹង បច្ចេកវិទ្យាព័ត៌មាននឹងរឹតតែនាំឲ្យនិស្សិតស្វែងរកបាននូវឯកសារដែលខ្លួនត្រូវការគ្រប់ពេលវេលា ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ៖

៩.៤.១ បំពាក់Internet and Wifi

៩.៤.២ បំពាក់ E-Library

៩.៥ តាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត ជាយុទ្ធសាស្ត្រមួយដែលធានាបាននូវការយកចិត្តទុកដាក់ខ្ពស់រវាងគណៈគ្រប់គ្រងសាកលវិទ្យាល័យជាមួយនឹងនិស្សិត។ ពីព្រោះការគ្រប់គ្រងលើសកម្មភាពសិក្សារបស់និស្សិត គឺអាចនឹងកំណត់បានពីការចូលរួមសិក្សារៀនសូត្ររបស់និស្សិត គ្រប់មុខវិជ្ជាទាំងអស់ ដែលសាកលវិទ្យាល័យតម្រូវឲ្យពួកគេសិក្សា។ ម្យ៉ាងវិញទៀត វាជាយុទ្ធសាស្ត្រដែលបង្ហាញពីនិទស្សន៍ និងជោគជ័យ លើការបណ្តុះបណ្តាលនិស្សិតគ្រប់កម្រិត និងគ្រប់ជំនាញទាំងអស់ តាមរយៈវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

៩.៥.១ គ្រប់គ្រងអវត្តមាននិស្សិត

៩.៥.២ ប្រឡងបញ្ចប់

៩.៥.៣ គ្រប់គ្រងរបាយការណ៍ស្រាវជ្រាវ

៩.៦ លើកទឹកចិត្តដល់និស្សិតឆ្នើម ជាយុទ្ធសាស្ត្រមួយ ដែលជួយជម្រុញឲ្យនិស្សិតទាំងអស់ខិតខំសិក្សារៀនសូត្រថែមមួយកំរិតទៀត តាមរយៈការលើកទឹកចិត្តដល់និស្សិតឆ្នើម ។ ដើម្បីឲ្យយុទ្ធសាស្ត្រ សម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួន ដូចខាងក្រោមនេះ៖

៩.៦.១ ផ្តល់ប័ណ្ណសរសើរ

៩.៦.១ ផ្តល់រង្វាន់លើកទឹកចិត្ត

១០.ផ្តល់នូវការអប់រំសិក្សាបន្ថែមដើម្បីពង្រឹងសមត្ថភាព គោលបំណងនេះ ជួយឲ្យនិស្សិតដែលកំពុងតែសិក្សានៅក្នុងសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច នឹងទទួលបាន នូវការសិក្សាជំនាញឯកទេស បន្ថែមជាច្រើនផ្សេងទៀត ដើម្បីអភិវឌ្ឍចំណេះដឹងនិស្សិតឲ្យកាន់តែទូលំទូលាយតម្រូវទៅតាមទីផ្សារការងារនាពេលបច្ចុប្បន្ន។ ជាពិសេស ការបើកវគ្គសិក្ខាសាលាសម្រាប់បណ្តុះបណ្តាលមានដូចជា៖ កិច្ចការរដ្ឋបាល វិទ្យាសាស្ត្រកុំព្យូទ័រ គណនេយ្យ ការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំជាដើម ។ល។

១០.១ បើកវគ្គសិក្ខាសាលានិងវគ្គសិក្សាខ្លី ជាយុទ្ធសាស្ត្រមួយដែលស្របតាម គោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដែលអនុញ្ញាតឲ្យគ្រឹះស្ថានអប់រំឧត្តមសិក្សាទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បញ្ចូលនូវកម្មវិធីសិក្សាបន្ថែម ដែលជាបញ្ហាប្រឈមសម្រាប់សង្គមជាតិនាពេលបច្ចុប្បន្នដូចជា៖ ការអប់រំពីច្បាប់ចរាចរណ៍ផ្លូវគោក ការអប់រំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ការអប់រំពីរបៀបការពារមិនអោយឆ្លងជំងឺអេដស៍និងជំងឺផ្សេងៗទៀតជាដើម ដល់និស្សិតដែលកំពុង តែសិក្សានៅក្នុងគ្រឹះស្ថានរបស់ខ្លួន។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញ នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ

១០.១.១ កំណត់កម្មវិធីសិក្ខាសាលា

១០.១.២ រៀបចំសិក្ខាសាលា និងវគ្គសិក្សាខ្លី

១០.១.៣ កំណត់កាលបរិច្ឆេទ

១០.១.៤ ជូនដំណឹងអំពីកម្មវិធី

១០.១.៥ វាយតម្លៃលើកម្មវិធី

១០.២សម្រង់មតិពីស្ថាប័នខាងក្រៅចំពោះមុខវិជ្ជាដែលចាំបាច់ ជាយុទ្ធសាស្ត្រមួយដ៏ចាំបាច់បំផុតលើដំណើរការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ជាពិសេសសម្រង់មតិនេះបង្ហាញឲ្យកាន់តែច្បាស់ពីតម្រូវការរបស់មជ្ឈដ្ឋានខាងក្រៅចំពោះមុខវិជ្ជា ដែលសាកលវិទ្យាល័យបានរៀបចំ និងដំណើរការ រៀនសូត្រដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១០.២.១ រៀបចំកម្រងសំណួរ

១០.២.២ រៀបចំកាលវិភាគចុះស្ទង់មតិ

១០.២.៣ ប្រមូល និងវិភាគទិន្នន័យ

១០.២.៤ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

១០.៣ សម្រង់មតិពីនិស្សិតចំពោះមុខវិជ្ជាដែលចាំបាច់ ជាយុទ្ធសាស្ត្រមួយដ៏ចាំបាច់បំផុតលើដំណើរការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ជាពិសេសសម្រង់មតិនេះបង្ហាញឲ្យកាន់តែច្បាស់ពីតំរូវការសិក្សារបស់និស្សិតចំពោះមុខវិជ្ជាដែលពួកគេកំពុងតែសិក្សា រៀនសូត្រដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១០.៣.១ រៀបចំកម្រងសំណួរ

១០.៣.២ រៀបចំកាលវិភាគចុះស្ទង់មតិ

១០.៣.៣ ប្រមូល និងវិភាគទិន្នន័យ

១០.៣.៤ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

១០.៤ ប្រឡងដើម្បីវាស់ស្ទង់កម្រិតយល់ដឹង ជាយុទ្ធសាស្ត្រមួយដែលកំណត់ពីសមត្ថភាពចំណេះដឹង និងគុណភាពអប់រំបណ្តុះបណ្តាលនិស្សិត នៅក្នុងសាកលវិទ្យាល័យតាមរយៈការប្រលងបញ្ចប់ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១០.៤.១ រៀបចំវិញ្ញាសា

១០.៤.១ រៀបចំកាលបរិច្ឆេទប្រឡង

១០.៤.១ ចេញលទ្ធប្រឡង

១១. បង្កើនការអភិវឌ្ឍសម្ភារូបវន្ត ដើម្បីឲ្យគោលបំណងមួយនេះ សម្រេចនឹងទទួលបានជោគជ័យ នឹងមានដំណើរការល្អវាជារឿងចាំបាច់បំផុត ដែលសាកលវិទ្យា ល័យគ្រប់គ្រង និង

សេដ្ឋកិច្ច ត្រូវអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការការពារសុវត្ថិភាព សន្តិសុខដល់និស្សិត។ ជាពិសេស កិច្ចការនេះ នឹងបម្រើផលប្រយោជន៍យ៉ាងច្រើនឲ្យបុគ្គលិក សាស្ត្រាចារ្យ និង និស្សិត ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ រួមមាន ភាគីដែលចូលរួម ដំណើរការ សម្ភារៈនិងបច្ចេកវិទ្យា សម្រាប់ប្រតិបត្តិការ លើបរិស្ថាន អាជីវកម្ម និង ការសិក្សា ហើយការងារនេះ ត្រូវផ្សារភ្ជាប់ទៅនឹងផ្នែកជាច្រើនទៀតរបស់សាកលវិទ្យាល័យដូចជាៈ ប្រព័ន្ធហិរញ្ញវត្ថុ កិច្ចការ រដ្ឋបាល បណ្ណាល័យ និងគ្រប់ការិយាល័យធ្វើការរបស់បុគ្គលិកផងដែរ។ តទៅថ្ងៃខាងមុខ គម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសិក្សាអប់រំនឹងត្រូវបានបន្តពង្រីកបន្ថែមទៀត ដើម្បីឲ្យសាកលវិទ្យាល័យឈានមុខគេ ក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សា ។

១១.១ គោលការណ៍គ្រប់គ្រងសម្ភាររូបវន្តជាដំណើរការប្រតិបត្តិមួយ ដ៏សំខាន់ក្នុងការធានាបាននូវការរៀបចំផែនការប្រើប្រាស់នូវសម្ភារៈរូបវន្តនានា ប្រកបដោយ ប្រពលភាព និងអាចទុកចិត្តបានក្នុងការផ្តល់នូវសេវាកម្មសិក្សា ដល់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រ សម្រេចបានសាកលវិទ្យាល័យបានដាក់ចេញ នូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ

១១.១.១ បង្កើតគណៈកម្មការគ្រប់គ្រង និង ថែរក្សាសម្ភារៈរូបវន្ត

១១.១.២ បង្កើតគោលការណ៍ប្រើប្រាស់ និង ជួសជុលសន្និធិនានា

១១.១.៣ កត់ត្រាជាប្រចាំខែនូវសម្ភារៈដែលប្រើប្រាស់

១១.១.៤ ធ្វើរបាយការណ៍លើសន្និធិដែលបានប្រើប្រាស់រួច

១១.២ ធានាឲ្យមានសម្ភាររូបវន្តគ្រប់គ្រាន់ស្របទៅនឹងតម្រូវការ ជាយុទ្ធសាស្ត្រមួយដែលកំណត់បានពីតម្រូវការរបស់និស្សិត ដែលកំពុងតែសិក្សានៅក្នុងសាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច ជាពិសេសយុទ្ធសាស្ត្រនេះអាចនឹងរកឃើញពីសេវាកម្មដែលត្រូវផ្តល់ឲ្យនិស្សិតដើម្បីឲ្យយុទ្ធសាស្ត្រ សម្រេចបានសាកលវិទ្យាល័យបានដាក់ចេញ នូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះៈ

១១.២.១ រៀបចំបុគ្គលិកសម្រាប់គ្រប់គ្រងសម្ភារៈរូបវន្ត

១១.២.២ វាស់វែងពីតម្រូវរបស់និស្សិតតាមរយៈសម្រង់មតិលើសេវាកម្មសិក្សា

១១.២.៣ គ្រប់គ្រងសម្ភារៈឧបទ្ទេសសិក្សាដែលត្រូវផ្តល់ឲ្យសាស្ត្រាចារ្យ និង និស្សិត

១១.២.៤ កំណត់ពីតម្រូវការនិស្សិតតាមរយៈសេចក្តីរាយការណ៍របស់ប្រធានថ្នាក់

១១.៣ ថែរក្សា និងជួសជុលសម្ភាររូបវន្ត ជាយុទ្ធសាស្ត្រមួយដ៏សំខាន់ក្នុងការគ្រប់គ្រងថែរក្សា និងជួសជុលសន្និធិនានា ដែលមាននៅក្នុងសាកលវិទ្យាល័យ។

១១.៤ ធ្វើទំនើបកម្មលើសម្ភាររូបវន្ត ជាយុទ្ធសាស្ត្រមួយ ដែលជម្រុញឲ្យសាកលវិទ្យាល័យខិតខំប្រឹងប្រែងបន្ថែមទៀតលើដំណើរការអភិវឌ្ឍអាគារ និង ទីតាំងឲ្យរឹតតែមានភាព ទាក់ទាញសម្រាប់និស្សិត និង ភ្ញៀវនានាដែលធ្វើទស្សនកិច្ចស្វែងយល់ ពីសាកលវិទ្យាល័យទាំងមូល ។ កត្តាដែលសំខាន់ជាងគេនោះ គឺបំពេញទៅលើតម្រូវការនិស្សិត តាមរយៈបច្ចេកវិទ្យាទាន់សម័យ ហើយនឹង

អាចចំណេញពេល វេលាបានច្រើន។ ដើម្បីឲ្យ យុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យបាន ដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១១.៩.១ រៀបចំឲ្យមានបុគ្គលិកគ្រប់គ្រងសម្ភារៈ

១១.៩.២ ជម្រុញឲ្យបុគ្គលិកគ្រប់គ្រងតាមដានការយកចេញ-ការយកចូលសម្ភារៈ

១១.៩.៣ ជម្រុញឲ្យបុគ្គលិកគ្រប់គ្រងរាយការណ៍ប្រចាំខែ

១១.៩.៤ ចាត់ឲ្យបុគ្គលិកជួសជុលសម្ភារៈដែលអាចប្រើប្រាស់បន្តទៀតបាន

១២. បង្កើននូវសេវាកម្មសិក្សា ៖ សេវាកម្មសិក្សា ជាមាគ៌ាមួយដ៏ចាំបាច់បំផុត លើវិស័យឯកជន ភាវូបនីយកម្ម ក្នុងការប្រកួតប្រជែងលើបរិបទសេដ្ឋកិច្ចសេរី ដើម្បីទទួលបាននូវភាពជោគជ័យ និង និរន្តរភាពការងារយូរអង្វែង។ គោលបំណងនេះ នឹងធ្វើឲ្យនិស្សិតកាន់តែមានទំនុកចិត្ត នឹង ជឿជាក់ ទៅលើសេវាកម្មសិក្សា ដែលសាកលវិទ្យាល័យបានផ្តល់ជូននិស្សិត និង សាធារណជនកន្លងមក ដោយសេវាកម្មទាំងអស់រួមមានការផ្តល់ព័ត៌មានសិក្សាការចុះឈ្មោះសិក្សា ការគ្រប់គ្រងចរន្តលិខិត ស្នាមរដ្ឋបាលជាដើម។លើសពីនេះទៅទៀត សម្ភារៈបច្ចេកទេសនឹងត្រូវបានអភិវឌ្ឍជាប្រចាំដើម្បី បម្រើសេវាកម្មឲ្យសាធារណជន រឹតតែបានស្គាល់សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច បន្ថែមទៀត ។

១២.១បង្កើតប្រព័ន្ធគ្រប់គ្រងលើសេវាកម្មសិក្សាជាយុទ្ធសាស្រ្តមួយ ដែលវាស់វែងឲ្យឃើញកាន់តែ ច្បាស់ពីតម្រូវការជាក់ស្តែង របស់និស្សិតទាំងអស់ តាមរយៈសម្រង់មតិស្រាវជ្រាវពីប្រភពមជ្ឈដ្ឋាន ផ្សេងៗ។ ការគ្រប់គ្រងលើតម្រូវការជាក់ស្តែងរបស់និស្សិតនេះ នឹងជួយឲ្យសាកលវិទ្យាល័យខិតខំ ផ្តល់សេវាកម្មសិក្សារបស់ខ្លួនជូនដល់និស្សិត ដោយផ្អែកលើមធ្យោបាយនិងធនធាន ដែលខ្លួន ដើម្បីធ្វើការកែលំអរឲ្យមានលក្ខណៈប្រសើរឡើងមួយកម្រិតទៀត។ ដើម្បីឲ្យ យុទ្ធសាស្រ្តសម្រេច បានសាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១២.១.១ ការរៀបចំកម្រងស្រាវជ្រាវ

១២.១.២ ទទួលសំបុត្ររិះគន់ដើម្បីស្ថាបនាតាមរយៈប្រអប់សំបុត្រ

១២.១.៣ ប្រជុំពិភាក្សាលើតម្រូវការរបស់និស្សិត

១២.១.៤ ផ្តល់លទ្ធផលឆ្លើយតបដល់និស្សិត

១២.១.៥ ប្រជុំដល់ការិយាល័យពាក់ព័ន្ធដើម្បីធ្វើការដោះស្រាយ

១២.២ការគ្រប់គ្រងលើដំណើរការប្រើប្រាស់បណ្ណាល័យ ជាយុទ្ធសាស្រ្តមួយដែលជម្រុញឲ្យនិស្សិត ទាំងអស់ប្រើប្រាស់បណ្ណាល័យជាកន្លែងផ្តល់ចំណេះដឹងដល់ពួកគេតាមរយៈការសិក្សាស្រាវជ្រាវ ។ ម្យ៉ាងវិញទៀត ដើម្បីឲ្យដំណើរការគ្រប់គ្រងបណ្ណាល័យមានលក្ខណៈល្អប្រសើរ សាកលវិទ្យាល័យ គ្រប់គ្រងនិងសេដ្ឋកិច្ចបានកំណត់នូវ សកម្មភាពមួយចំនួនដូចខាងក្រោម៖

១២.២.១ ចាត់តាំងបុគ្គលិកគ្រប់គ្រងបណ្ណាល័យ

១២.២.២ បង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់បណ្ណាល័យ

១២.២.៣ រៀបចំឯកសារតាមដានសកម្មភាពចូលអាន និងប្រើប្រាស់អ៊ីនធឺណែត

១២.២.៤ បើកវគ្គបណ្តុះបណ្តាលបន្ថែមសម្រាប់បណ្ណារក្ស

១២.២.៥ ប្រជុំបូកសរុបការងារបណ្ណារក្សប្រចាំខែ

១២.៣ គាំទ្រទៅលើសកម្មភាពបង្រៀននិងសិក្សាស្រាវជ្រាវ ជាយុទ្ធសាស្ត្រមួយដែលជម្រុញលើកទឹកចិត្តដល់និស្សិតគ្រប់រូបខិតខំប្រឹងប្រែងបន្ថែមទៀត។ ជាពិសេសការលើកកំពស់ សកម្មភាពបង្រៀន និងសិក្សាស្រាវជ្រាវជាវិធានមួយដ៏ចាំបាច់សម្រាប់ការអប់រំបណ្តុះបណ្តាល។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១២.៣.១ ផ្តល់រង្វាន់លើកទឹកចិត្តដល់គ្រូបង្រៀន

១២.៣.២ ជួយបោះពុម្ពស្នាដៃរបស់ពួកគាត់

១២.៣.៣ ជម្រុញឲ្យគ្រូបង្រៀនដែលបទពិសោធន៍ល្អចែករំលែកគ្រូផ្សេងទៀត

១២.៣.៤ ជួយសម្របសម្រួលសកម្មភាពបង្រៀនរបស់ពួកគាត់

១២.៤ជម្រុញ និងអភិវឌ្ឍសេវាប្រើប្រាស់ **Computer and Internet** ជាយុទ្ធសាស្ត្រមួយដែលនឹងជម្រុញឲ្យនិស្សិតទាំងអស់យ៉ាងហោចណាស់ក៏៨០ភាគរយ ចេះប្រើប្រាស់កុំព្យូទ័រដូចជាកិច្ចការរដ្ឋបាល ការរៀបចំឯកសារទិន្នន័យ ជាពិសេសនិស្សិតអាចចេះស្វែងរកព័ត៌មានតាមរយៈបណ្តាញប្រព័ន្ធអ៊ីនធឺណែត ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយ ចំនួនដូចខាងក្រោមនេះ៖

១២.៤.១ ការបង្រៀនកុំព្យូទ័រដោយមិនគិតថ្លៃសិក្សា

១២.៤.២ ការជ្រើសរើសនិស្សិតឲ្យចូលសិក្សាពីរបៀបស្វែងរកព័ត៌មានតាមរយៈអ៊ីនធឺណែត

១២.៤.៣ ការវាយតម្លៃលើលទ្ធផលសិក្សានិស្សិតក្រោយពេលបញ្ចប់វគ្គ

១២.៤.៤ ចេញវិញ្ញាបនបត្រជូននិស្សិត

១២.៤.៥ បូកសរុបលទ្ធផលនៃវគ្គបណ្តុះបណ្តាលនីមួយ ៗ

១២.៥ សម្រួលការចេញលិខិត និងឯកសារផ្សេងៗ ជាយុទ្ធសាស្ត្រមួយ ដែលនឹងធានាបាននូវការគ្រប់គ្រងទិន្នន័យសិក្សានិងការផ្តល់នូវសេវាកម្មដល់និស្សិត មានប្រសិទ្ធភាពខ្ពស់ហើយងាយស្វែងរកដោយចំណាយពេលវេលាតិច ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ

១២.៥.១ បើកវគ្គបណ្តុះបណ្តាលបុគ្គលិកពីរបៀបគ្រប់គ្រងទិន្នន័យនិងព័ត៌មានផ្ទាល់

១២.៥.២ ជម្រុញល្បឿននៃការចេញនូវលិខិតបញ្ជាក់ការសិក្សាផ្សេងៗ ឲ្យកាន់តែល្អជាមុន

១២.៥.៣ ការបូកសរុបចំនួននិស្សិតគ្រប់ជំនាន់ និង គ្រប់កំរិតសិក្សា

១២.៥.៤ ការចែកជូនវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរៀងរាល់ចុងឆ្នាំសិក្សា

១២.៥.៥ រៀបចំប្រព័ន្ធគ្រប់គ្រងលទ្ធផលសិក្សារបស់និស្សិតគ្រប់ជំនាន់

១៣. បង្កើនចំនួននិស្សិតមានការងារធ្វើ គោលបំណងនេះគឺជាសេចក្តីប្រាថ្នាដ៏ចម្បងជាងគេបង្អស់សម្រាប់និស្សិតដែលកំពុងតែសិក្សានិង និស្សិតដែលនឹងត្រូវបញ្ចប់ការសិក្សា ពីព្រោះនៅពេលដែលនិស្សិតមានការងារ ធ្វើកាន់តែច្រើននាក់ នោះមានន័យថា និស្សិតពិតជាបាន កែប្រែជីវភាពរស់នៅរបស់ខ្លួន នឹងកំពុងតែជួយអភិវឌ្ឍប្រទេសជាតិ។ ដើម្បីធានាបាននូវសមភាពការងារនិងទំហំការងារកើនឡើង ចំណុចដែលសាកលវិទ្យាល័យបានយកចិត្តទុកដាក់ខ្លាំងជាងគេគឺការចងទំនាក់ទំនងរវាងសាកលវិទ្យាល័យជាមួយនឹងអង្គការ ឬក៏ក្រុមហ៊ុននានា ឲ្យឃើញកាន់តែច្បាស់អំពីគុណភាពសិក្សា និង សមត្ថភាពការងាររបស់និស្សិត ។

១៣.១ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិករបស់ស្ថាប័ននានា ជាយុទ្ធសាស្ត្រមួយដែលធ្លាប់ទទួលបានជោគជ័យនាពេលកន្លងមកតាមរយៈការបិទផ្សាយជ្រើសរើសបុគ្គលិកពីបណ្តាក្រុមហ៊ុន អង្គការ និងគ្រឹះស្ថាននានាទាំងផ្នែករដ្ឋនិងឯកជន ដើម្បីផ្តល់ឱកាសដល់និស្សិតគ្រប់រូបត្រៀមលក្ខណៈរបស់ខ្លួនក្នុងស្វែងរកការងារធ្វើ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ៖

១៣.១.១ រៀបចំបុគ្គលិកទំនាក់ទំនង និង ស្រាវជ្រាវពីការងារ

១៣.១.២ បិទប្រកាសផ្សាយដំណឹងជ្រើសរើសបុគ្គលិកនៅលើក្តារខៀនផ្តល់ព័ត៌មាន

១៣.១.៣ ផ្សព្វផ្សាយដំណឹងនៅតាមថ្នាក់រៀន

១៣.១.៤ បណ្តុះបណ្តាលបន្ថែមដល់និស្សិតពីរបៀបស្វែងរកការងារធ្វើ

១៣.១.៥ គ្រប់គ្រងទិន្នន័យនិស្សិតដែលមានការងារធ្វើក្នុងកំឡុងពេលសិក្សា និងក្រោយបញ្ចប់ការសិក្សា

១៣.២ រៀបចំសិក្ខាសាលាជាមួយអង្គការ ក្រុមហ៊ុន ស្តីពីតម្រូវការធនធានមនុស្សជាយុទ្ធសាស្ត្រមួយដែលជួយឲ្យសាកលវិទ្យាល័យកាន់តែមានភាពស្និទ្ធស្នាល និងជាទីទុកចិត្តលើការងារបណ្តុះបណ្តាលធនធានរបស់ខ្លួន ចំពោះតម្រូវការគ្រឹះស្ថាននានា។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ

១៣.២.១ អញ្ជើញម្ចាស់សហគ្រាសក្រុមហ៊ុននិងអង្គការនានាមកធ្វើបទបង្ហាញពីតម្រូវការរបស់ខ្លួន

១៣.២.២ បន្តចុះអនុស្សារណៈដល់បណ្តាក្រុមហ៊ុន អង្គការ និង គ្រឹះស្ថាននានាដែលចង់ចងសម្ព័ន្ធមេត្រីភាព

១៣.២.៣បញ្ជូនតំលៃសិក្សាដល់បុគ្គលិកអង្គការ ក្រុមហ៊ុន និងគ្រឹះស្ថានដែលបានចុះ MoU ជាមួយ

១៣.២.៤ ចុះធ្វើការស្រាវជ្រាវពីតម្រូវការរបស់ក្រុមហ៊ុន និង អង្គការ

១៣.៣ ជម្រុញនិស្សិតឲ្យមានសមត្ថភាព (ជំនាញ កុំព្យូទ័រ អង់គ្លេស និងក្រមសីលធម៌) ជាបុព្វហេតុដ៏ចម្បងក្នុងការប្រកួតប្រជែងការងារនៅលើទីផ្សារនាពេលបច្ចុប្បន្ន។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ៖

១៣.៣.១ វគ្គសិក្សាជំនាញ

១៣.៣.២ សិក្ខាសាលា

១៣.៣.៣ ក្លឹបសិក្សាភាសាអង់គ្លេស

១៣.៣ តាមដាន និងគ្រប់គ្រងអត្រានិស្សិតមានការងារធ្វើ ជាយុទ្ធសាស្ត្រដែលធ្វើឲ្យសាកលវិទ្យាល័យឃើញច្បាស់លើលទ្ធផលនៃការផលិត ធនធានមនុស្សរបស់ខ្លួនលើតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៣.៣.១ ស្រង់ស្ថិតិតាមក្រុមហ៊ុន និងស្ថាប័ននានាក្នុងខេត្ត

១៣.៣.២ ស្រង់ស្ថិតិតាមWebsite UME

១៣.៣.៣ បូកសរុបស្ថិតិ និងរបាយការណ៍(១ ឆ្នាំ)

១៣.៤ ទំនាក់ទំនង និងសម្របសម្រួលរកទីកន្លែងឲ្យនិស្សិតចុះ ធ្វើកម្មសិក្សា ជាយុទ្ធសាស្ត្រមួយដែលជម្រុញឲ្យនិស្សិតទាំងអស់ទទួលបាននូវឱកាសសម្រាប់ធ្វើកម្មសិក្សា និងទស្សនកិច្ចសិក្សា ស្មើភាពនៅតាមបណ្ដាក្រុមហ៊ុន អង្គការ និងសហគ្រាសនានា ដើម្បីជាបទពិសោធន៍ការងារ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ៖

១៣.៤.១ ចុះអនុស្សារណៈយោគយល់ជាមួយនឹងស្ថាប័នផ្សេងៗ

១៣.៤.២ ទំនាក់ទំនងក្រុមហ៊ុន អង្គការ និងស្ថាប័នរដ្ឋ

១៣.៤.៣ រៀបចំកាលវិភាគ និងក្រុមចុះកម្មសិក្សា

១៣.៤.៤ ធ្វើរបាយការណ៍

១៤.លើកកំពស់ការចូលរួមនិងអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ គោលបំណងនេះធ្វើឲ្យនិស្សិតមានទំលាប់ធ្វើការរស់នៅជាមួយនឹងសហគមន៍ ជាពិសេសនិស្សិតនឹងបានជួយអប់រំយុវជនដូចគ្នាដែលកំពុងតែរស់នៅក្នុងសហគមន៍ឲ្យជៀសផុតពីការសេពគ្រឿងញៀននិង អំពើអបាយមុខនានា។ ក្នុងនោះដែរ ការបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានរបស់សាកលវិទ្យាល័យ ជាប្រភពនាំសារមួយដ៏សំខាន់ក្នុងការផ្តល់ព័ត៌មាន សិក្សាអប់រំ សុខភាព ស្ថានភាព នយោបាយ និង សេដ្ឋកិច្ច និងនាទីកំសាន្តជូនដល់និស្សិត និងសាធារណជនទូទៅដោយឆ្លុះបញ្ចាំងអំពីទស្សនវិស័យ និងបេសកកម្មរបស់ខ្លួនក្នុងពាក្យស្លោកបណ្តុះបណ្តាលធនធានមនុស្សសំរាប់ថ្ងៃនេះ និង ថ្ងៃស្អែក ។

១៤.១ ទំនាក់ទំនងជាមួយអាជ្ញាធរ និងសហគមន៍ ជាយុទ្ធសាស្ត្រដែល សាកលវិទ្យាល័យប្រកាន់ខ្ជាប់នូវទំនាក់ទំនងឲ្យកាន់តែមានលក្ខណៈប្រសើរថែម ទៀតជាមួយនឹងអាជ្ញាធរមូលដ្ឋានតាមរយៈ

ការអញ្ជើញអាជ្ញាធរគ្រប់លំដាប់ថ្នាក់ជាគណៈអធិបតី និង ជាអ្នកសម្របសម្រួលលើសកម្មភាពនានាដែលសាកលវិទ្យាល័យត្រូវការ។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ

១៩.១.១ រៀបចំលិខិតផ្លូវការ

១៩.១.២ ចុះទំនាក់ទំនងផ្ទាល់

១៩.២ ជំរុញឲ្យនិស្សិតចូលរួមនៅក្នុងសហគមន៍ ជាយុទ្ធសាស្រ្តមួយ ដែលជម្រុញឲ្យនិស្សិតទាំងអស់ ដែលកំពុងតែសិក្សាមានឱកាសចូលរួមធ្វើជាមួយនឹងសហគមន៍នានា នៅក្នុងទីរួមខេត្តបាត់ដំបងនិងបណ្តាស្រុកមួយចំនួនទៀតតាមរយៈសកម្មភាពនានា ដែលសហគមន៍ទាំងអស់ត្រូវការ។ ជាពិសេសយុទ្ធសាស្រ្តបែបនេះ នឹងធ្វើឲ្យនិស្សិតមានការយល់កាន់ខ្ពស់អំពីកិច្ចការងារផ្សេងៗ ដែលទ្រទ្រង់នូវជីវភាពរស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដូចជា៖ ការដកស្ទូង ការច្រូតកាត់ជាដើម ។ល។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូច ខាងក្រោមនេះ៖

១៩.២.១ បង្ហាញអត្ថប្រយោជន៍នៃការចូលរួម

១៩.២.២ បណ្តុះគំនិតនិស្សិតឲ្យស្រឡាញ់សហគមន៍

១៩.៣លើកទឹកចិត្តដល់និស្សិតដែលធ្វើការជាមួយនឹងសហគមន៍ ជាកាតព្វកិច្ចស្នូលមួយ ក្នុងការធានាបានឲ្យនិស្សិតគ្រប់រូបចេះបរិច្ចាគធនធានរបស់ខ្លួនមួយចំណែក ដើម្បីជួយសង្រ្គោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយសារហេតុការណ៍ណាមួយនៅក្នុងសង្គម ជាពិសេស ការជួយសង្រ្គោះដល់ប្រជាជននៅតាមទីជនបទនានាដែលកំពុងជួបប្រទះបញ្ហាកង្វះខាតស្បៀង។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៩.៣.១ ជូនប័ណ្ណសរសើរ

១៩.៣.២ ផ្តល់អាទិភាពការងារ

១៩.៤ បណ្តុះបណ្តាលឲ្យនិស្សិតយល់ដឹងពីមនុស្សធម៌និងការសង្រ្គោះបឋម ជាយុទ្ធសាស្រ្តមួយដែលជម្រុញឲ្យនិស្សិតទាំងអស់យល់ដឹងពីរបៀបនៃការសង្រ្គោះមនុស្ស ជាលក្ខណៈបឋមពីព្រោះវាជារឿងចាំបាច់បំផុតសម្រាប់ជួយមនុស្សដែលរងគ្រោះ ដោយសារឧបទ្ទវហេតុណាមួយផ្សេងៗ។ ដើម្បីឲ្យយុទ្ធសាស្រ្តសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៩.៤.១ រៀបចំសិក្ខាសាលាស្តីពីការសង្រ្គោះបឋម

១៤.៤.២ ផ្សព្វផ្សាយព័ត៌មាន

១៤.៥ បង្កើតព្រឹត្តិបត្រផ្សព្វផ្សាយប្រចាំត្រីមាស ជាប្រភពព័ត៌មានមួយដ៏សំខាន់ក្នុងផ្សព្វផ្សាយឲ្យនិស្សិតនិងសាធារណៈជនទូទៅបានជ្រាបកាន់តែច្បាស់ថែមទៀត តាមរយៈសកម្មភាពគោលបំណងនិងទស្សនៈវិស័យនានា ដែលឆ្លុះបញ្ចាំងពីតំលៃនៃការអប់រំសំរាប់កំរិតឧត្តមសិក្សា ព័ត៌មានជាតិ-អន្តរជាតិសេដ្ឋកិច្ចសង្គមវប្បធម៌និងសិល្បៈកំសាន្តនានា ដែលមានបោះពុម្ពផ្សាយជាព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបានសាកលវិទ្យាល័យបានដាក់ចេញ នូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ៖

១៤.៥.១ បង្កើតសមាសភាពគណៈកម្មការនិពន្ធ

១៤.៥.២ ការចុះស្រាវជ្រាវព័ត៌មាន

១៤.៥.៣ រៀបចំចងក្រងព័ត៌មានសម្រាប់បោះពុម្ពផ្សាយ

១៤.៥.៤ ការចេញផ្សាយព្រឹត្តិបត្ររៀងរាល់១ឆមាសម្តង

១៥. ធានាបាននូវការគ្រប់គ្រងផែនការថវិកា ការគ្រប់គ្រងគម្រោងថវិកា និងផែនការប្រើប្រាស់ថវិកា ជាគោលបំណងមួយមានអាទិភាពជាងគេ ក្នុងការធ្វើឲ្យ ដំណើរការផ្សេងៗ ប្រព្រឹត្តទៅបានយ៉ាងរលូន នឹងធានាបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយស្ថិតស្ថេរ។ ដើម្បីឲ្យគោលបំណងនេះសម្រេចបាន សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ចបានកំណត់ការងារ ឲ្យការិយាល័យរដ្ឋបាលនិង ហិរញ្ញវត្ថុ ជាអ្នកអនុវត្ត ការងារ ។

១៥.១ គោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ជាយុទ្ធសាស្ត្រមួយ ដែលនឹង កំណត់បាន នូវការគ្រប់គ្រងហរិញ្ញវត្ថុមួយមានលក្ខណៈច្បាស់លាស់និងជាលក្ខណៈប្រព័ន្ធ ដើម្បីធានាបាននូវស្ថេរភាពនៃការប្រើប្រាស់ហរិញ្ញវត្ថុ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាព មួយចំនួនដូច ខាងក្រោមនេះ

១៥.១.១ បង្កើតការិយាល័យគ្រប់គ្រងហិរញ្ញវត្ថុ

១៥.១.២ បែងចែងពីគោលការណ៍ទូទាត់ប្រាក់បៀវត្សបុគ្គលិក និង គ្រូបង្រៀន

១៥.១.៣ កំណត់ចំណូល និង ចំណាយ តាមរយៈការបង់ថ្លៃសិក្សានិស្សិត

១៥.១.៤ ធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនគណៈគ្រប់គ្រង

១៥.២ ធ្វើផែនការហិរញ្ញវត្ថុ និងការលើកផែនការថវិកាប្រចាំឆមាស និងឆ្នាំ ជាយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីធានាបាននូវការប្រើប្រាស់ថវិការួមមួយឲ្យមានប្រសិទ្ធិភាពតម្លាភាព និងគណនេយ្យភាពខ្ពស់តាមរយៈការប្រមូលបានពីការបង់ថ្លៃសិក្សារបស់និស្សិត។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៥.២.១ ផែនការចំណូលចំណាយ

១៥.២.២ រៀបចំគម្រោងថវិការយៈពេលវែង

១៥.៣សវនកម្មហិរញ្ញវត្ថុផ្ទៃក្នុង ជាយុទ្ធសាស្ត្រមួយដ៏មានប្រសិទ្ធិភាពខ្ពស់បំផុត ក្នុងការកំណត់បាននូវប្រព័ន្ធសវនកម្មហិរញ្ញវត្ថុមាន លក្ខណៈល្អប្រសើរ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៥.៣.១ រៀបចំគោលការណ៍ និងនីតិវិធី

១៥.៣.២ រៀបចំសមាសភាពគណៈកម្មការហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង

១៥.៣.៣ រៀបចំកាលវិភាគ ចុះធ្វើសវនកម្មផ្ទៃក្នុង

១៥.៣.៤ រៀបចំរបាយការណ៍

១៦.ធានាបាននូវការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង គោលបំណងនេះនឹងកំណត់បាននូវគុណភាពសិក្សាការបង្រៀនរបស់សាស្ត្រាចារ្យ និងការបម្រើការងាររបស់និយោជិតទាំងអស់កំពុងតែសិក្សានឹងធ្វើការនៅក្នុងសាកលវិទ្យាល័យនាពេលបច្ចុប្បន្ន ឲ្យឃើញពីចំណុចខ្លាំងនិងចំណុចខ្វះខាតរបស់ខ្លួនដើម្បីធ្វើការកែលំអនឹងពង្រឹង ចំណុចខ្លាំងឲ្យកាន់តែល្អប្រសើរថែមទៀត។ ដំណើរការនៃការវាយតម្លៃនេះតម្រូវឲ្យមានគណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងមួយ មានយុត្តិធម៌ត្រឹមត្រូវ និង ស្វ័យតភាព ។

១៦.១ បង្កើតគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ជាយុទ្ធសាស្ត្រមួយ ដែលនឹងកំណត់បាននូវគោលការណ៍វាយតម្លៃមួយជាក់លាក់ និងមានសុក្រឹតភាពក្នុងការធានា ឲ្យមានការងារគ្រប់គ្រងអប់រំ និងសិក្សាមួយប្រកបដោយគុណភាព និង ប្រសិទ្ធិភាពខ្ពស់ លើស្ថានភាពបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សានាពេលបច្ចុប្បន្ន។ ជាពិសេសគណៈកម្មការនេះ ចាំបាច់ត្រូវតែមានយុត្តិធម៌អព្យាក្រឹតនិងតម្លាភាព។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យ បានដាក់ចេញនូវសកម្មភាព មួយចំនួនដូចខាងក្រោមនេះ៖

១៦.១.១ ជ្រើសតាំងសមាសភាព

១៦.១.២ រៀបចំនីតិវិធី និងគោលការណ៍

១៦.១.៣ កំណត់តួនាទី និងភារកិច្ច

១៦.២ បង្កើតក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង

១៦.២.១ ជូនដំណឹងជ្រើសរើស

១៦.២.២ ពិនិត្យ CV

១៦.២.៣ បិតផ្សាយលទ្ធផលជ្រើសរើស

១៦.២.៤ រៀបចំកាលវិភាគសម្ភាសន៍

១៦.២.៥ សម្រេចជ្រើសរើស

១៦.២.៦ បណ្តុះបណ្តាល

១៦.៣ ផ្សព្វផ្សាយ នឹង ជូនដំណឹងស្តីពីការវាយតម្លៃគុណភាពអប់រំ ជាយុទ្ធសាស្ត្រមួយដែល គណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងជាអ្នកប្រតិបត្តិលើសកម្មភាពការងារជាក់ស្តែង។ដើម្បីឲ្យ យុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៦.៣.១ ផ្សព្វផ្សាយ និងជូនដំណឹងតាមរយៈ Website សិក្ខាសាលា និងព្រឹត្តបត្រព័ត៌មាន

១៦.៤ រង្វាយតម្លៃលើសកម្មភាពការងារដែលបានអនុវត្ត ជាយុទ្ធសាស្ត្រមួយដែលនឹងអាច កំណត់បានពីភាពទទួលខុសត្រូវរបស់គណៈកម្មការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងការិយាល័យដែលពាក់ព័ន្ធលើសកម្មភាពរបស់ខ្លួនបានអនុវត្តនាពេលកន្លងមក។ ដើម្បីឲ្យ យុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

១៦.៤.១ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពការងារ

១៦.៤.២ បូកសរុបលទ្ធផលនៃការវាយតម្លៃ

៦.៥ ប្រកាសលទ្ធផលនៃការវាយតម្លៃ ជាយន្តការមួយដ៏សំខាន់ក្នុងការសម្រេចឲ្យបាន ប្រព័ន្ធការងារមួយមានលក្ខណៈច្បាស់លាស់អាចទុកចិត្តបានពីអ្នកវាយតម្លៃនិង អ្នកត្រូវគេវាយតម្លៃតាមរយៈការប្រកាសលទ្ធផលវាយតម្លៃ។ ដើម្បីឲ្យយុទ្ធសាស្ត្រសម្រេចបាន សាកលវិទ្យាល័យបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោមនេះ

១៦.៥.១ ចេញលទ្ធផលវាយតម្លៃសម្រាប់គ្រូបង្រៀន

១៦.៥.២ ចេញលទ្ធផលវាយតម្លៃសម្រាប់ការិយាល័យនីមួយៗ

១៦.៥.៣ ជូនប័ណ្ណសរសើរប្រចាំឆ្នាំដល់គ្រូបង្រៀនដែលមានចំណាត់ថ្នាក់វាយតម្លៃល្អ

១៦.៥.៤ ជូនប័ណ្ណសរសើរដល់ការិយាល័យដែលអនុវត្តការងារបានល្អ

១៦.៥.៥ ធ្វើរបាយការណ៍សរុបលទ្ធផលប្រចាំឆ្នាំ

## VI- **សេចក្តីសន្និដ្ឋាន**

សរុបមក ការរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំរបស់សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ពិតជាឆ្លុះបញ្ចាំងនូវតម្រូវការរបស់សាធារណៈជនក្នុងវិស័យអប់រំឧត្តមសិក្សាដោយស្របតាមទស្សនវិស័យ ចក្ខុវិស័យ បេសកកម្ម និងគោលបំណងរួមរបស់អង្គភាព។

ដើម្បីសម្រេច ឲ្យបាននូវផែនការយុទ្ធសាស្រនេះ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចប្តេជ្ញានឹងខិតខំប្រឹងប្រែងអនុវត្ត ដោយលើផ្អែកលើភារកិច្ចទទួលខុសត្រូវទៅតាមផ្នែកនីមួយៗ ជាពិសេស ផែនការនេះ ក៏នឹងជាមគ្គុទេសន៍មួយដ៏សំខាន់ផងដែរសម្រាប់ទិសដៅអភិវឌ្ឍន៍អង្គភាពទាំងមូល ។

ធ្វើបាត់ដំបង ថ្ងៃទី......ខែ........ឆ្នាំ ២០១១

ប្រធានក្រុមប្រឹក្សាភិបាល

## សាររបស់ឯកឧត្តមសាកលវិទ្យាធិការ

ផែនការយុទ្ធសាស្ត្រសំរាប់សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ចរយៈពេល ៥ ឆ្នាំ (២០១០-២០១៥) ជាសមិទ្ធិផលមួយដ៏ត្រចះត្រចង់ ដែលបង្ហាញនូវយុទ្ធសាស្ត្រ និងសកម្មភាពនានាសំរាប់គណៈគ្រប់គ្រងក៏ដូចជាការិយាល័យផ្សេងទៀត នៅក្នុងសាកលវិទ្យាល័យអនុវត្តការងាររបស់ខ្លួននាពេលខាងមុខ។ស្នាដៃនេះបានឆ្លុះបញ្ចាំងពីបញ្ញាញាណ របស់ថ្នាក់ដឹកនាំសាកលវិទ្យាល័យជាពិសេស គ្រប់ផ្នែកទាំងអស់របស់សាកលវិទ្យាល័យ ដែលបនឆ្លងកាត់បទពិសោធន៍លើការងារបណ្តុះបណ្តាលនិស្សិត។ ក្នុងរយៈពេលកន្លងមកនេះ យើងបានពុះពារ សាកល្បងជំនះលើឧបសគ្គ និងការលំបាកជាច្រើន ដើម្បីងើបឈរឡើង និងដើរឆ្ពោះទៅកាន់អនាគតដ៏រុងរឿង ប្រកបដោយកិត្តិយសលើ វិស័យអប់រំនិស្សិត កំរិតថ្នាក់ឧត្តមសិក្សានៅកម្ពុជា ។

ការរៀបចំផែនការយុទ្ធសាស្ត្រនេះ ផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើដំណើរការរៀបចំការងារ និង នីតិវិធីផ្សេងៗទៀតអោយមានលក្ខណៈជាប្រព័ន្ធអប់រំតាមស្តង់ដារជាតិ និងអន្តរជាតិ ។ ផែនការយុទ្ធសាស្ត្រនេះ ប្រមូលផ្តុំលើកឡើងនូវចក្ខុវិស័យ និងទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗច្បាស់លាស់ដែលសាកលវិទ្យាល័យត្រូវអនុវត្តក្នុងរយៈពេលខ្លីមធ្យម និងវែងឆ្ងាយនៅពេលខាងមុខទៀត ។

វិធីសាស្រ្តក្នុងការដាក់អនុវត្តន៍ផែនការយុទ្ធសាស្រ្តនេះ តម្រូវអោយត្រៀមខ្លួនបត់បែនទន់ភ្លន់ រស់រវើក និងច្នៃប្រឌិតស្របតាមកាលៈទេសៈ ពេលវេលា និងជំហានរីកចំរើនជាក់ស្តែងនៃការអភិវឌ្ឍន៍ រីកចំរើនសេដ្ឋកិច្ចសង្គម និងការអប់រំបណ្តុះបណ្តាលធនធាន មនុស្សនៅកម្ពុជាស្របតាម គោលនយោបាយរបស់ រាជរដ្ឋាភិបាលកម្ពុជាដោយមានវិស័យអប់រំសិក្សាធិការ ជាកត្តាអាទិភាពក្នុងការដឹកនាំនិងអភិវឌ្ឍន៍សង្គមជាតិ អោយមានការរីកចំរើនដូចជាអារ្យប្រទេសនានានៅលើសាកលលោក ក្នុងបរិបទសកលលោកភាវូបនីយកម្ម និង ឯកជនភាវូបនីយកម្ម ។

ការត្រួតពិនិតឡើងវិញទៅតាមតំណាក់កាលនីមួយៗ នៃការរៀបចំផែនការយុទ្ធសាស្រ្តរយៈ ៥ ឆ្នាំ (២០១០-២០១៥) ពិតជានឹង ឆ្លើយតបបានទាន់ពេលវេលាចំពោះតំរូវការថ្មីៗ ចំពោះមុខសាកលវិទ្យាល័យ គ្រប់គ្រង និង សេដ្ឋកិច្ច ។ ការយកចិត្តទុកដាក់តាមដាន លើលទ្ធផល និងសកម្មភាពរីកចំរើនផងទាំងឡាយ ក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្រ្តត្រូវអមមកជាមួយដោយជំហានកែលំអនិងតំរង់ទិសដៅជាបន្តបន្ទាប់សំដៅកំណត់អោយឃើញនូវអាទិភាពថ្មី និងកាត់បន្ថយនូវភាពខ្វះចន្លោះអវិជ្ជមានហើយប្រមូលផ្តុំបាននូវគ្រប់ថាមពលសកម្ម ដើម្បីធានាអោយផែនការយុទ្ធសាស្រ្តនេះដើរទៅមុខដោយរលូនច្បាស់លាស់ ត្រូវតាមកំណត់ពេល ពេលវេលា និងជោគជ័យ ក្នុងការពង្រឹងគុណភាពសិក្សានៅកម្ពុជា ។

ជាចុងបញ្ចប់ សាកលវិទ្យាល័យគ្រប់គ្រង និង សេដ្ឋកិច្ច ជឿជាក់ថា ផែនការយុទ្ធសាស្រ្តនេះជាប្រទីបរួមមួយក្នុងការបំភ្លឺផ្លូវឆ្ពោះទៅកាន់វឌ្ឍនភាព ដែលជាក្តីសង្ឃឹមសំរាប់យើងទាំងអស់គ្នា ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយផ្អែកលើគុណតំលៃរបស់ សាកលវិទ្យាល័យរួមមាន ៖ គុណភាព ភាពក្លាហាន មោះមុត ក្រមសីលធម៌ និង មនសិការជាតិ ។

បាត់ដំបង ថ្ងៃ.............ទី.............ខែ...........ឆ្នាំ ២០១.....

**សាកលវិទ្យាធិការ**